ក

មាតិកា

I~ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

08-02-2007	-KRET NS / KRT / 0207 / 055 NOMMONS Monsieur Paul Bin Héng, Grand Officier de l'Ordre Royal du Cambodge, en témoignage de Notre très haute considération .	២៦០៨
09-02-2007	-KRET NS / KRT / 0207 / 056 DECERNONS à titre posthume Monsieur le Docteur Sompon Sahawat , la Grand' Croix de l'Ordre Royal du Sahamétrei, en témoignage de Notre plus haute considération .	២៦០៩
១២-២-២០០៧	-ព្រះរាជក្រឹត្យ នស/រកត/០២០៧/០៥៧ ស្តីពីការតែងតាំង ឯកឧត្តម **ខែក ឡាំចេ** ជា ឧត្តមប្រឹក្សាផ្ទាល់ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា	២៦១០
០២-៣-២០០៧	-ព្រះរាជក្រឹត្យ នស/រកត/០៣០៧/១០១ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ដុងហូ ឆយ** (DONGHO CHOI) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតនៅខេត្តប៊ូសាន សាធារណរដ្ឋកូរ៉េ	២៦១១
០៦-៣-២០០៧	-ព្រះរាជក្រឹត្យ នស/រកត/០៣០៧/១០៤ ស្តីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ជូនឯកឧត្តម និងលោកជំទាវ ចំនួន ១០ រូប	២៦១២
០៦-៣-២០០៧	-ព្រះរាជក្រឹត្យ នស/រកត/០៣០៧/១០៥ ស្តីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ជូនឧកញ៉ា និងឯកឧត្តម ចំនួន ០៣ រូប	២៦១៣
០៦-៣-២០០៧	-ព្រះរាជក្រឹត្យ នស/រកត/០៣០៧/១០៦ ស្តីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតូបការ និងគ្រឿង ឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ជូនឯកឧត្តម , ឧកញ៉ា ,លោក និងលោកជំទាវ ចំនួន ១២ រូប	២៦១៤
១០-៣-២០០៧	-ព្រះរាជក្រឹត្យ នស/រកត/០៣០៧/១០៧ ស្តីពីការប្រោសព្រះរាជទាន ចំពោះ ឯក ឧត្តម **ហោ ណាំបុង** នូវគ្រឿង ឥស្សរិយយស ជាតូបការ	២៦១៥

១០-៣-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៣០៧/១០៨ ស្ដីពីការបង្កើត នាយកដ្ឋាន បុគ្គលិក និង ធនធានមនុស្ស នៅក្នុងរចនាសម្ព័ន្ធចាត់តាំងរបស់ក្រសួងព្រះបរមរាជវាំង ដែលមានចែងក្នុងមាត្រា ២ នៃព្រះរាជក្រឹត្យលេខ NS / KRT -34 ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ១៩៩៦ ២៦១៦

II.រាជរដ្ឋាភិបាល

១.អនុក្រឹត្យ

១៩-៣-២០០៧ -អនុក្រឹត្យលេខ ២៣ អនក្រ.បក ស្ដីពីការប្ដូរឈ្មោះ សាកលវិទ្យាល័យ ញូវតុនធីឡាយ ទៅជា សាកលវិទ្យាល័យសុវណ្ណភូមិ ២៦១៧

១៩-៣-២០០៧ -អនុក្រឹត្យលេខ ២៤ អនក្រ.បក ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ២៦២០

១៤-៣-២០០៧ -អនុក្រឹត្យលេខ ២០៣ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ២៦៣៧

១៤-៣-២០០៧ -អនុក្រឹត្យលេខ ២០៤ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ២៦៣៨

១៥-៣-២០០៧ -អនុក្រឹត្យលេខ ២០៥ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ២៦៣៩

១៥-៣-២០០៧ -អនុក្រឹត្យលេខ ២០៦ អនក្រ.តត ស្ដីពីការជូនមេដាយសុវត្ថារា ២៦៤០

១៥-៣-២០០៧ -អនុក្រឹត្យលេខ ២០៧ អនក្រ.តត ស្ដីពីការជូនមេដាយការងារ ២៦៤១

១៥-៣-២០០៧ -អនុក្រឹត្យលេខ ២០៨ អនក្រ.តត ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ ២៦៥១

១៥-៣-២០០៧ -អនុក្រឹត្យលេខ ២០៩ អនក្រ.តត ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ ២៦៥៣

១៥-៣-២០០៧ -អនុក្រឹត្យលេខ ២១០ អនក្រ.តត ស្ដីពីការជូនមេដាយការងារ ២៦៥៤

១៥-៣-២០០៧ -អនុក្រឹត្យលេខ ២១១ អនក្រ.តត ស្ដីពីការតម្លើងឋានន្តរស័ក្ដិ នាយទាហាន ២៧០៤

១៥-៣-២០០៧ -អនុក្រឹត្យលេខ ២១២ អនក្រ.តត ស្ដីពីការតម្លើងឋានន្តរស័ក្ដិ នាយនគរបាលជាតិ ២៧០៦

១៥-៣-២០០៧ -អនុក្រឹត្យលេខ ២១៣ អនក្រ.តត ស្ដីពីការបន្ថែមក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ ២៧០៧

២.សេចក្ដីសំរេច

១៩-៣-២០០៧ -សេចក្ដីសំរេចលេខ ១៤ សសរ ស្ដីពី សប្ដាហ៍ជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក ២៧០៨

III-ការងារបណ្ណាក្រសួង

១-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

១៧-០១-២០០៧ -ប្រកាសលេខ ០៩៨ សហវ ស្តីពីការផ្តល់អាជ្ញាប័ណ្ណជូនក្រុមហ៊ុនធានារ៉ាប់រងទូទៅ ឬអាយុជីវិត ២៧០៩

១៥-៣-២០០៧ -ប្រកាសអន្តរក្រសួងលេខ ១៨០ សហវ.ប្រក ស្តីពីការកំណត់ និង កែសម្រួលប្រាក់ឧបត្ថម្ភគោលនយោបាយប្រចាំខែ ជូនកូនរបស់គ្រួសារជនពលី និង មរណៈ ២៧១៩

២-ទីស្តីការរដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

១២-៣-២០០៧ -ប្រកាសលេខ៤១ក.ធ.ស.ប្រក ស្តីពីការបង្កើតសាលាពុទ្ធិកអនុវិទ្យាល័យកៀនស្វាយ ២៧២១

១២-៣-២០០៧ -ប្រកាសលេខ ៤២ ក.ធ.ស.ប្រក ស្តីពីការបង្កើតសាលាពុទ្ធិកអនុវិទ្យាល័យសម្តេច **ជា ស៊ីម** វត្តត្រពាំងឈូក ២៧២៣

១២-៣-២០០៧ -ប្រកាសលេខ ៤៣ ក.ធ.ស.ប្រក ស្តីពីការបង្កើតសាលាពុទ្ធិកអនុវិទ្យាល័យ វត្តសិត្បូ ២៧២៥

១២-៣-២០០៧ -ប្រកាសលេខ ៤៤ ក.ធ.ស.ប្រក ស្តីពីការបង្កើតសាលាពុទ្ធិកអនុវិទ្យាល័យ ក្រពើហា ២៧២៧

៣-ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

០២-០១-២០០៧ -លិខិតបញ្ជាក់លេខ ០០០៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ីម ហ្គោល អ៊ិនវេស្តមិនណល ខូ អិលធីឌី** ២៧២៩

០២-០១-២០០៧ -លិខិតបញ្ជាក់លេខ ០០០៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខ្មែរ សុតមង្គល គ្រុប** ២៧៣១

០៣-០១-២០០៧ -លិខិតបញ្ជាក់លេខ ០០០៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អិល.ទី.ស៊ី.ខនស្ទេន** ២៧៣៣

០៣-០១-២០០៧ -លិខិតបញ្ជាក់លេខ០០២១ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនិងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ីធីស្តារ អ៊ិនវេសមេន** ២៧៣៥

ច្បាប់ចម្លង

KRET

NS / KRT / 0207 / 1055

Nous

Preah Karuna Preah Bat Samdech

Preah Boromneath Norodom Sihamoni

Roi du Cambodge

NOMMONS

Monsieur Paul Bin Héng,

Grand Officier de l'Ordre Royal du Cambodge,

en témoignage de Notre très haute considération.

៣/ល.០៧០២.០៦៥

Norodom Sihamoni

បានប្រទាប់ព្រះរាជលញ្ឆករហើយ

Fait au Palais Royal à Phnom Penh, le 8 Février 2007

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
លេខ : ០០៥/០៧ រ.ចច
រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ កុម្ភៈ ឆ្នាំ ២០០៧
សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីវង្ស
ឧបនាយករដ្ឋមន្ត្រី និងជា រដ្ឋមន្ត្រីព្រះបរមរាជវាំង

គង់ សំអុល

ច្បាប់ចម្លង

KRET

NS / KRT / 0207 / 056

Nous

Preah Karuna Preah Bat Samdech

Preah Boromneath Norodom Sihamoni

Roi du Cambodge

DECERNONS

à titre posthume

Monsieur le Docteur Sompon Sahawat,

la Grand'Croix de l'Ordre Royal du Sahamétrei,

en témoignage de Notre plus haute considération.

៣ស.០៧០២.០៦៦

Norodom Sihamony

បានប្រទាប់ព្រះរាជលញ្ឆករហើយ

Fait au Palais Royal à Phnom Penh, le 9 Février 2007

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

លេខ: [illegible] រ.ចច

រាជធានីភ្នំពេញ, ថ្ងៃទី ..៩.... ខែ [illegible]..... ឆ្នាំ ២០០៧

សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីឧឡុង

ឧបនាយករដ្ឋមន្ត្រី និងជា រដ្ឋមន្ត្រីព្រះបរមរាជវាំង

គង់ សំអុល

ច្បាប់ចម្លង

ព្រះរាជក្រឹត្យ

នស/រកត/០២០៧/០៥៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

តែងតាំង

ឯកឧត្តម ខែក ឡឺរ៉ាង

ជា

ឧត្តមប្រឹក្សាផ្ទាល់
ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

ព.រ.ល.០៧០២.០៦៧

បានប្រថាប់ព្រះរាជលញ្ឆករហើយ

ន សីហមុនី

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០៧

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
លេខ : ០០[illegible]/០៧ រ.ចច
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៧
សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីធរ
ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីព្រះបរមរាជវាំង

គង់ សំអុល

ព្រះរាជក្រឹត្យ

នស/រកត/០៣០៧/១០១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានគុណជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក ដុងហូ ឆយ (DONGHO CHOI) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៦៥ នៅខេត្តប៊ូសាន សាធារណរដ្ឋកូរ៉េ ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះ តទៅ ។

ព្រះហស្ថលេខា និងព្រះរាជលញ្ជករ
នរោត្តម សីហមុនី

៣៧.០៧០៣.១១១

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០០៧

លេខៈ ១២៤ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ... ខែ មីនា ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល
... ចិនកេន

នស/រកត/០៣០៧/១០៤

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរិវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ទូវ

ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ចំពោះ :

១-ឯកឧត្តម ឃួង ថែម

២-ឯកឧត្តម ប្រាក់ ហាម

៣-ឯកឧត្តម ឆេង សារឿន

៤-ឯកឧត្តម ស៊ុយ នូ

៥-ឯកឧត្តម ម៉ៅ សម្បត្តិ

ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា ចំពោះ :

១-ឯកឧត្តម ភង ណែម

២-ឯកឧត្តម ពូ ដារ៉ានី

គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ ចំពោះ :

១-ឯកឧត្តម ស៊ុំ រ៉ុំ

២-ឯកឧត្តម ឌុច សុវណ្ណារី

៣-លោកជំទាវ ឃុន លក្ខី

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.០៧០៣.១១៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ មីនា ឆ្នាំ ២០០៧

លេខ:១២៦.ច.ល
ចម្លងចេញពីច្បាប់ដើម
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ៣ ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ជិនកេង

ព្រះរាជក្រឹត្យ

នស/រកត/០៣០៧/១០៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានត្ថបិជាតិសាសនា រក្សាខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពោហភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្ត្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

ក. គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ

-ឧកញ៉ា ម៉ក់ គឹមហុង

ខ. គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ចំពោះ :

១-ឯកឧត្តម ញ៉ែម ថ្លាវី

២-ឯកឧត្តម ណាំ ធុំ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរល.០៧០៣.១១៥

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ មីនា ឆ្នាំ ២០០៧

លេខ: ១២៧៥ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

យ៉ុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៣០៧/១០៦

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្ដិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ក-គ្រឿងឥស្សរិយយស ជាតូបការ ចំពោះ :

- ឯកឧត្ដម ញឹម វណ្ណដា

ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ :

-ឯកឧត្ដម ពៅ សាមី

គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ចំពោះ :

១-ឯកឧត្ដម ហខ្យ សារឿន
២-ឯកឧត្ដម ប៊ុន ណារិទ្ធិ
៣-ឯកឧត្ដម ប៊ូន លឹមហេង
៤-ឯកឧត្ដម ហ៊ី បាវី
៥-លោកជំទាវ នុង សុគន្ធ
៦-ឧកញ៉ា ស្វះ សារិទ្ធិ
៧-លោក អាំង យូម៉េង
៨-លោក ជា ឈីស្រ៊ុន

ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ចំពោះ :

១-ឯកឧត្ដម និត ហ៊ើល
២-លោក ឡាំ ហេងឃួត

ព្រះហស្ដលេខា និងព្រះរាជលញ្ឆករ
នរោត្ដម សីហមុនី

ព.រ.ល.០៧០៣.១១៦

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ មីនា ឆ្នាំ ២០០៧

លេខ ៦២៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ចាន់ថុល

ព្រះរាជក្រឹត្យ

នស/រកត/០៣០៧/១០៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ឯកឧត្តម ហោ ណាំហុង

នូវ

គ្រឿងឥស្សរិយយស ជាតូបការ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.០៧០៣.១១៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០០៧

លេខៈ ១២៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ០៣ ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល
ឃួន ជិនកេន

ច្បាប់ចម្លង

ព្រះរាជក្រឹត្យ

នស/រកត/០៣០៧/១០៨

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានគ្គមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ NS / KRT- 34 ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ១៩៩៦ ស្រាស់បង្គាប់បង្កើតក្រសួងព្រះបរមរាជវាំង
- បានទ្រង់យល់ព្រះរាជក្រឹត្យ នស /រកត /០៨០៤ /១៦៥ ចុះថ្ងៃទី ០២ ខែសីហា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងសម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីង្គារ គង់ សំអុល ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង
- បានទ្រង់យល់នូវសេចក្តីត្រូវការចាំបាច់ចំពោះមុខ

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានបង្កើត **នាយកដ្ឋាន បុគ្គលិក និងធនធានមនុស្ស** នៅក្នុងរចនាសម្ព័ន្ធចាត់តាំងរបស់ក្រសួងព្រះបរមរាជវាំង ដែលមានចែងក្នុងមាត្រា២ នៃព្រះរាជក្រឹត្យលេខ NS / KRT- 34 ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ១៩៩៦ ។

មាត្រា ២ : ប្រគល់ជូន សម្តេចចៅហ្វាវាំង ឧបនាយករដ្ឋមន្ត្រី និងជា រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង រៀបចំ និងកំណត់តួនាទីភារកិច្ចនៃនាយកដ្ឋាននេះ ។

មាត្រា ៣ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេច ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានបញ្ញត្តិ ចាប់ពីពេលឡាយព្រះហស្តលេខាតទៅ ។

៣រល.០៧០៣.១១៨

ន សីហមុនី

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង .រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០០៧

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
លេខ ០៨៤/០៧ រ.ចច
រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០០៧
សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីង្គារ
ឧបនាយករដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីព្រះបរមរាជវាំង

គង់ សំអុល

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២៣ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការប្តូរឈ្មោះ សាកលវិទ្យាល័យញូវគុនធីឡាយ

ទៅជា សាកលវិទ្យាល័យសុវណ្ណភូមិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក. ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០០៤ ស្តីពីការទទួលស្គាល់សាកលវិទ្យាល័យញូវគុនធីឡាយ
- បានឃើញយោបល់របស់ក្រសួងអប់រំ យុវជន និងកីឡា តាមលិខិតលេខ ៩៩១ អយក.ឧស ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០០៧

ស ម្រេ ច

មាត្រា ១ : ទទួលស្គាល់ការប្តូរឈ្មោះ **សាកលវិទ្យាល័យបញ្ញាសាស្ត្រនុទ័ឡាយ** ទៅជា **សាកលវិទ្យាល័យសុវណ្ណភូមិ** " SOVANNAPHUMI UNIVERSITY " ហៅកាត់ជាភាសាខ្មែរ " ស.ស.ភ " និងហៅកាត់ជាភាសាអង់គ្លេស " SPU " ។ សាកលវិទ្យាល័យនេះ មានទីតាំងស្ថិតនៅអគារលេខ ១៣១ ផ្លូវលេខ ១៤៣ កែងផ្លូវលេខ ៣៦៨ សង្កាត់បឹងកេងកង ៣ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

មាត្រា ២ : សាកលវិទ្យាល័យសុវណ្ណភូមិ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៣ : សាកលវិទ្យាល័យសុវណ្ណភូមិ មានភារកិច្ច :

- បណ្តុះបណ្តាលអ្នកជំនាញឯកទេសឧត្តមសិក្សាគ្រប់កម្រិត ស្របតាមបេសកកម្មរបស់ សាកលវិទ្យាល័យ
- បង្កើនសមត្ថភាពមុខជំនាញបច្ចេកទេសដល់គ្រូបង្រៀន និងសាស្ត្រាចារ្យ សម្រាប់សាកលវិទ្យាល័យសុវណ្ណភូមិ
- រៀបចំកម្មវិធីសិក្សា ឱ្យស្របតាមតម្រូវការទីផ្សារការងារ ស្តង់ដារអន្តរជាតិ និងបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា
- សិក្សាស្រាវជ្រាវខ្លឹមសារនៃការសិក្សា វិធីសាស្ត្របង្រៀន និងចងក្រងឯកសារបច្ចេកទេសវិទ្យាសាស្ត្រជាភាសាជាតិ និងភាសាបរទេស ឱ្យបានសមស្របសម្រាប់ប្រើប្រាស់
- រៀបចំ និងដំណើរការជ្រើសរើសនិស្សិតឱ្យចូលរៀន ប្រឡងចេញ និងស្វ័យវាយតម្លៃលើការសិក្សាឱ្យបានត្រឹមត្រូវ តាមគោលការណ៍ និងប្រកបដោយតម្លាភាព
- ធ្វើការស្រាវជ្រាវវិទ្យាសាស្ត្រ តាមឯកទេសរបស់សាកលវិទ្យាល័យសុវណ្ណភូមិ
- កសាងផែនការអភិវឌ្ឍ សម្រាប់សាកលវិទ្យាល័យសុវណ្ណភូមិ
- គ្រប់គ្រងនិយោជិក កម្មករ និស្សិត សាស្ត្រាចារ្យ និងទ្រព្យសម្បត្តិរបស់ សាកលវិទ្យាល័យសុវណ្ណភូមិ
- ធ្វើកិច្ចសហប្រតិបត្តិការជាមួយអង្គការជាតិ អន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល និងស្ថាប័ននានា ក្នុងគោលបំណងធ្វើឱ្យកាន់តែល្អប្រសើរឡើងនូវការសិក្សា ការបង្រៀន និងការស្រាវជ្រាវ ។

មាត្រា ៤ : សាកលវិទ្យាល័យសុវណ្ណភូមិ ធ្វើការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិត ដែលរចនាសម្ព័ន្ធសិក្សាត្រូវបានរៀបចំ ឱ្យមានមហាវិទ្យាល័យប្រាំ :

- មហាវិទ្យាល័យសិល្បៈ មនុស្សសាស្ត្រ និងភាសា
- មហាវិទ្យាល័យគណិតសាស្ត្រ និងវិទ្យាសាស្ត្រ
- មហាវិទ្យាល័យវិទ្យាសាស្ត្រសង្គម និងសេដ្ឋកិច្ច
- មហាវិទ្យាល័យគ្រប់គ្រងពាណិជ្ជកម្ម និងទេសចរណ៍
- មហាវិទ្យាល័យព័ត៌មានវិទ្យា និងទូរគមនាគមន៍

ទៅអនាគត សាកលវិទ្យាល័យសុវណ្ណភូមិ អាចប្តូរឈ្មោះ ប្តូរទីតាំង ពង្រីកទីតាំង ធ្វើកិច្ចសហប្រតិបត្តិការជាមួយនឹងគ្រឹះស្ថានឧត្តមសិក្សាបរទេស ឬបើកមហាវិទ្យាល័យ សាខា ឯកទេស ឬប្រភេទអប់រំដទៃទៀត ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពី ក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៥ : សាកលវិទ្យាល័យសុវណ្ណភូមិ មានក្រុមប្រឹក្សាភិបាលមួយ ដើម្បីពិនិត្យ និងសម្រេច លើគោលនយោបាយ ផែនការអភិវឌ្ឍសាកលវិទ្យាល័យ និងការងារបច្ចេកទេសពាក់ព័ន្ធដទៃទៀត ។

មាត្រា ៦ : តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងជាក់ស្តែង នៃសាកលវិទ្យាល័យសុវណ្ណភូមិ ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាលរបស់សាកលវិទ្យាល័យ និងដោយមានការឯកភាពពី ក្រសួងអប់រំ យុវជន និងកីឡា។

មាត្រា ៧ : សាកលវិទ្យាល័យសុវណ្ណភូមិ ត្រូវគ្រប់គ្រងដោយសាកលវិទ្យាធិការមួយរូប ដែលមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា។

មាត្រា ៨ : សាកលវិទ្យាធិការ មានភារកិច្ច :

- ទទួលខុសត្រូវចំពោះមុខច្បាប់ ក្នុងការគ្រប់គ្រងសាកលវិទ្យាល័យសុវណ្ណភូមិ
- រៀបចំផែនការយុទ្ធសាស្ត្រ សម្រាប់អភិវឌ្ឍន៍សាកលវិទ្យាល័យសុវណ្ណភូមិ
- ទទួលបន្ទុកអនុវត្តបទដ្ឋានទាំងឡាយរបស់រាជរដ្ឋាភិបាល និងរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលពាក់ព័ន្ធទៅនឹងការងារបណ្តុះបណ្តាល
- ធ្វើរបាយការណ៍គ្រប់គ្រងប្រចាំឆមាស ប្រចាំឆ្នាំ និងសកម្មភាពផ្សេងៗទៀត ជូនក្រសួងអប់រំ យុវជន និងកីឡា តាមការកំណត់
- កំណត់ការរៀបចំរចនាសម្ព័ន្ធ និងភារកិច្ច ដល់អង្គភាពនានាក្រោមឱវាទ
- បំពេញតួនាទីតាមឋានានុក្រម ចំពោះបុគ្គលិកទាំងអស់របស់សាកលវិទ្យាល័យសុវណ្ណភូមិ និងគោរពតាមវិធានការ ស្តីពីការគ្រប់គ្រងបុគ្គលិក
- កំណត់បទបញ្ជាផ្ទៃក្នុង នៃសាកលវិទ្យាល័យសុវណ្ណភូមិ
- ត្រូវធានាឱ្យមានសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម
- ជាតំណាងរបស់សាកលវិទ្យាល័យ ក្នុងការទំនាក់ទំនងជាមួយតតិយជន ។

មាត្រា ៩ : និស្សិតដែលបានរៀនចប់កម្មវិធីសិក្សារបស់សាកលវិទ្យាល័យសុវណ្ណភូមិ និងទទួលបានជោគជ័យ ក្នុងការប្រឡងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាបត្រតាមកម្រិត និងតាមឯកទេសដែលបានសិក្សា។ សញ្ញាបត្រនេះ ផ្តល់ឱ្យដោយសាកលវិទ្យាល័យសុវណ្ណភូមិ ហើយមានការទទួលស្គាល់ពី ក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណីសាកលវិទ្យាល័យនេះ បំពេញ និងអនុវត្តបានតាមគោលការណ៍ និងបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ១០ : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ១១ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាកលវិទ្យាល័យសុវណ្ណភូមិ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- សាលាក្រុងភ្នំពេញ
- ដូចមាត្រា ១១
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៨ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

******

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើ, ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០០៧

ស ម្រេ ច

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

អនុក្រឹត្យនេះមានគោលដៅរៀបចំបណ្តាអង្គភាព នៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងកំណត់បេសកកម្មរបស់ក្រសួង និងមុខងារនៃអគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាពនានាក្រោមឱវាទ ។

ជំពូកទី ២
បេសកកម្ម និង រចនាសម្ព័ន្ធ

មាត្រា ២.-

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាប្រគល់បេសកកម្មឱ្យដឹកនាំ និងគ្រប់គ្រងវិស័យវប្បធម៌ និង វិចិត្រសិល្បៈ នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៣.-

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ មានមុខងារ និងភារកិច្ច ដូចតទៅ ÷

- ប្រតិបត្តិនូវនយោបាយការពារ ថែរក្សា និងលើកតម្លៃ បេតិកភណ្ឌវប្បធម៌ជាតិ និងសម្បត្តិវប្បធម៌ទូទៅនៃព្រះរាជាណាចក្រកម្ពុជា គ្រប់គ្រងរមណីយដ្ឋានវប្បធម៌ បុរាណវិទ្យា នរវិទ្យា និងប្រវត្តិវិទ្យា
- ផ្ដុំឡើងវិញ និងលើកតម្កើងបណ្ដាតម្លៃវប្បធម៌ និងជំនឿទំនៀមទម្លាប់ ប្រពៃណីរបស់សង្គមជាតិ បំផុសការបង្កើតស្នាដៃ ផ្សព្វផ្សាយ និងអភិវឌ្ឍន៍សកម្មភាពវប្បធម៌
- ជាអាណាព្យាបាលបច្ចេកទេសលើសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ក្នុងការបណ្ដុះបណ្ដាលសិល្បករ តន្ត្រីករ ស្ថាបត្យករ បុរាណវិទូ និងអ្នកជំនាញផ្សេងៗទៀតដែលពាក់ព័ន្ធនឹងវិស័យវប្បធម៌ ដោយសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៤.-

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ មានរចនាសម្ព័ន្ធដូចតទៅ ÷

ក. ថ្នាក់កណ្ដាល :

- ខុទ្ទកាល័យ រដ្ឋមន្ត្រី
- អធិការដ្ឋាន
- នាយកដ្ឋាន សវនកម្មផ្ទៃក្នុង
- អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ
- អគ្គនាយកដ្ឋាន បច្ចេកទេសវប្បធម៌
- អគ្គនាយកដ្ឋាន បេតិកភណ្ឌ
- សាលាមធ្យមវិចិត្រសិល្បៈ ។

ខ. អង្គភាពមូលដ្ឋាន :

- មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត-ក្រុង
- ការិយាល័យវប្បធម៌ និងវិចិត្រសិល្បៈ ស្រុក-ខណ្ឌ ។

គ. គ្រឹះស្ថានសាធារណៈ ៖

- សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ។

អង្គការលេខរបស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

ជំពូកទី ៣
ខុទ្ទកាល័យរដ្ឋមន្ត្រី

មាត្រា ៥.-

ខុទ្ទកាល័យរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មទាំងឡាយដែលកំណត់តាមបទប្បញ្ញត្តិ នៃអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ដូចមានយោងក្នុងមូលបទខាងលើ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន។

ជំពូកទី ៤
អធិការដ្ឋាន

មាត្រា ៦.-

អធិការដ្ឋានរបស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ មានភារកិច្ចដូចតទៅ ÷

- ធ្វើអធិការកិច្ចជាប្រចាំ ទៅលើគ្រប់អង្គភាពក្រោមឱវាទក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រី ពីការប្រព្រឹត្តទៅរបស់អង្គភាពដែលបានធ្វើអធិការកិច្ចហើយនោះ និងពីមធ្យោបាយកែលម្អការប្រព្រឹត្តទៅរបស់អង្គភាពទាំងនោះ
- ប្រតិបត្តិភារកិច្ច តាមកាលដែលរដ្ឋមន្ត្រីបានប្រគល់ជូន។

អធិការដ្ឋានដឹកនាំដោយអធិការមួយរូប អមដោយអធិការរងមួយ ឬច្រើនរូបជាជំនួយការ តាមការចាំបាច់។

ជំពូកទី ៥
នាយកដ្ឋាន សវនកម្មផ្ទៃក្នុង

មាត្រា ៧.-

នាយកដ្ឋានសវនកម្មផ្ទៃក្នុង ទទួលបន្ទុកអនុវត្តមុខងារ និងភារកិច្ច តាមខ្លឹមសារអនុក្រឹត្យលេខ ៤០ អនក្រ. បក ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃសវនកម្មផ្ទៃក្នុង នៅតាមបណ្តាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ។

ជំពូកទី ៦

អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

មាត្រា ៨.-

អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ មានមុខងារដូចតទៅ ÷

- គ្រប់គ្រងការងាររួមមាន : រដ្ឋបាល បូកសរុប របាយការណ៍ ឯកសារ បុគ្គលិក ផែនការ ស្ថិតិ ហិរញ្ញវត្ថុ សម្ភារៈបរិក្ខារ ការងារបណ្តុះបណ្តាលក្របខ័ណ្ឌក្រសួង ការងារសហប្រតិបត្តិការវប្បធម៌អន្តរជាតិ និងកិច្ចការអាស៊ាន ការងារសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល និងនីតិកម្ម

- សម្របសម្រួលរាល់សកម្មភាពរដ្ឋបាលនៅក្នុងក្រសួង ជាមួយបណ្តាអង្គភាពមូលដ្ឋានខេត្ត-ក្រុង និងជាមួយបណ្តាក្រសួងនានា។

មាត្រា ៩.-

អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ត្រូវបានដឹកនាំដោយអគ្គនាយកមួយរូប និងអមដោយអគ្គនាយករងមួយចំនួន ជាជំនួយការតាមការចាំបាច់។

អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ មាននាយកដ្ឋានចំណុះចំនួន ៨ (ប្រាំបី) និងសាលាបណ្តុះបណ្តាលក្របខ័ណ្ឌវប្បធម៌ថ្នាក់ស្មើនាយកដ្ឋាន ÷

១- នាយកដ្ឋាន រដ្ឋបាលទូទៅ

២- នាយកដ្ឋាន បុគ្គលិក

៣- នាយកដ្ឋាននីតិកម្ម

៤- នាយកដ្ឋាន គណនេយ្យ និង ហិរញ្ញវត្ថុ

៥- នាយកដ្ឋាន សម្ភារៈ និងបរិក្ខារ

៦- នាយកដ្ឋាន ផែនការ ស្ថិតិ និងសរុប

៧- នាយកដ្ឋាន សិទ្ធិអ្នកនិពន្ធ និង សិទ្ធិប្រហាក់ប្រហែល

៨- នាយកដ្ឋាន សហប្រតិបត្តិការវប្បធម៌ អន្តរជាតិ និង កិច្ចការអាស៊ាន

៩- សាលាបណ្តុះបណ្តាលក្របខ័ណ្ឌវប្បធម៌។

មាត្រា ១០.-

នាយកដ្ឋានរដ្ឋបាលទូទៅ មានភារកិច្ចដូចតទៅ ÷

- សម្របសម្រួលសកម្មភាពគ្រប់ផ្នែករបស់ក្រសួងនៅថ្នាក់កណ្តាល និងរវាងថ្នាក់កណ្តាល និងអង្គភាពមូលដ្ឋានក្រោមឱវាទ

- គ្រប់គ្រង និងចរាចរឯកសាររដ្ឋបាលផ្សេងៗរបស់ក្រសួង

- ធានាប្រសិទ្ធភាព សុវត្ថិភាពរដ្ឋបាល

- រក្សា និងតម្កល់ឯកសាររបស់ក្រសួង
- គ្រប់គ្រងប្រពន្ធ័ពត៌មានវិទ្យា
- ធ្វើរបាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន
- ទទួលអនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន ។

នាយកដ្ឋានរដ្ឋបាលទូទៅ ដឹកនាំដោយប្រធានមួយរូប និង អនុប្រធានមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

មាត្រា ១១.-

នាយកដ្ឋានបុគ្គលិក មានភារកិច្ចដូចតទៅ ÷

- គ្រប់គ្រងផ្នែករដ្ឋបាលមន្ត្រីរាជការ និងភ្នាក់ងាររាជការរបស់ក្រសួង ដោយធ្វើទំនាក់ទំនងនឹងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- រៀបចំរាល់លិខិតរដ្ឋបាល សម្រាប់ការគ្រប់គ្រងអាជីព
- ធ្វើកម្មវិធីពីតំណែង ឯកទេស និងធនធានមនុស្សរបស់ក្រសួង
- វាយតម្លៃតម្រូវការ ក្នុងការបណ្តុះបណ្តាលបុគ្គលិក និងពិនិត្យបញ្ជូនមន្ត្រីជំនាញទៅធ្វើសុក្រឹតការ ឬបន្តការសិក្សានៅក្នុង និងក្រៅប្រទេស
- រៀបចំនយោបាយបណ្តុះបណ្តាលដំបូង និងបន្ត ដោយធ្វើទំនាក់ទំនងនឹងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ដើម្បីអនុវត្តនយោបាយនោះ
- រៀបចំការប្រឡងជ្រើសរើសបញ្ចូលក្របខ័ណ្ឌក្រសួងឱ្យសមស្រប តាមនយោបាយរួមរបស់ក្រសួង
- រៀបចំស្ថិតិលើការគ្រប់គ្រងបុគ្គលិក និងតារាងព័ត៌មានប្រតិបត្តិ
- គ្រប់គ្រងការងារសង្គមរបស់ក្រសួង
- សហការជាមួយបណ្តាអង្គភាព និងគ្រឹះស្ថានសិក្សាបច្ចេកទេសវប្បធម៌ ដើម្បីចូលរួមកសាងកម្មវិធីសិក្សា និងសកម្មភាពរបស់អង្គភាពទាំងនោះ សម្រាប់ការបណ្តុះបណ្តាលឱ្យស្របទៅតាមតម្រូវការអភិវឌ្ឍនៃសង្គមជាតិ
- លើកសំណើបង្កើត ឬរំសាយអង្គភាពនានា រៀបចំតួនាទី ភារកិច្ច កែសម្រួលរចនាសម្ព័ន្ធ តាមស្ថានភាពជាក់ស្តែង
- ធ្វើរបាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន
- ទទួលអនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន ។

នាយកដ្ឋានបុគ្គលិក ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់ ។

មាត្រា ១២.-

នាយកដ្ឋាននីតិកម្ម មានភារកិច្ចដូចតទៅ ÷

- សិក្សា ស្រាវជ្រាវ ឯកសារច្បាប់ជាតិ អន្តរជាតិ និងលិខិតបទដ្ឋាននានាពាក់ព័ន្ធលើការគ្រប់គ្រងវិស័យវប្បធម៌ និងលើកយោបល់ជូនថ្នាក់ដឹកនាំក្រសួង
- រៀបចំ កសាងផែនការច្បាប់ និងលិខិតបទដ្ឋាននានារបស់ក្រសួង
- រៀបចំ តាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋាននានា លើវិស័យវប្បធម៌ ដោយធ្វើការទំនាក់ទំនងជាមួយអង្គភាពជំនាញ និងស្ថាប័នអ្នកច្បាប់
- ចងក្រង និងតម្កល់ទុករាល់ឯកសារច្បាប់ទាំងឡាយពាក់ព័ន្ធលើវិស័យវប្បធម៌
- ផ្សព្វផ្សាយ និងតាមដានការអនុវត្តច្បាប់ និងលិខិតបទដ្ឋាននានារបស់វិស័យវប្បធម៌ ដល់បណ្តាអង្គភាពនាយកដ្ឋាន និងគ្រឹះស្ថានដែលពាក់ព័ន្ធ
- ធ្វើរបាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន
- ទទួលអនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន ។

នាយកដ្ឋាននីតិកម្ម ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់ ។

មាត្រា ១៣.-

នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ មានភារកិច្ចដូចតទៅ ÷

- ប្រមូលចំណូល ឱ្យបានសមស្របតាមច្បាប់ហិរញ្ញវត្ថុដែលបានកំណត់
- លើកគម្រោងថវិកាក្រសួង និងតាមដានរំលឹកពីការប្រតិបត្តិ
- ប្រមូលផ្តុំ និងសម្របសម្រួលជំពូកថវិកា
- តាមដាន រំលឹក ការគ្រប់គ្រងគណនីពិសេស
- ប្រមូលផ្តុំ និងសម្របសម្រួលរាល់ចំណាយរបស់ក្រសួង
- គ្រប់គ្រងបន្ទុកគណនីរបស់ការអនុវត្តលទ្ធកម្មសាធារណៈ
- ធ្វើរបាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន
- ទទួលអនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន ។

នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយ ការតាមការចាំបាច់ ។

មាត្រា ១៤.-

នាយកដ្ឋានសម្ភារៈ និងបរិក្ខារ មានភារកិច្ចដូចតទៅ ÷

- ប្រមូលផ្តុំតម្រូវការ ធ្វើកម្មវិធីចំណាយ គ្រប់គ្រងការរៀបចំផ្គត់ផ្គង់សម្ភារៈ និង បរិក្ខាររបស់ក្រសួង
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សទ្ធិធិសម្ភារៈ និងធ្វើបញ្ជីសារពើភ័ណ្ឌ

- គ្រប់គ្រងយានដ្ឋាន និងយានយន្តរបស់រដ្ឋដែលប្រគល់ជូនក្រសួង ព្រមទាំងធ្វើកម្មវិធីចំណាយ និងបែងចែកប្រេងឥន្ធនៈ និងគ្រឿងបន្លាស់
- ទទួល និងបែងចែកបរិក្ខារជូនដល់បណ្តាអង្គភាព ខេត្ត-ក្រុងនានា
- កាន់បញ្ជីជាប្រចាំនូវសលាកប័ត្រ និងគណនេយ្យរូបធាតុ
- ត្រួតពិនិត្យបច្ចេកទេសនៃការប្រតិបត្តិលទ្ធកម្មសាធារណៈ
- ព័ត៌មានវិទ្យាសកម្មភាពខាងហិរញ្ញវត្ថុ និងបន្ទុកគណនី
- ធ្វើរបាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន
- ទទួលអនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន។

នាយកដ្ឋានសម្ភារៈ និងបរិក្ខារ ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួន ជាជំនួយការ តាមការចាំបាច់។

មាត្រា ១៥.-

នាយកដ្ឋានផែនការ ស្ថិតិ និង សរុប មានភារកិច្ចដូចតទៅ÷

- ធ្វើឱ្យសម្រេច និងផ្សព្វផ្សាយនូវការងារសិក្សាស្រាវជ្រាវ និងបូកសរុប ដែលពាក់ព័ន្ធនឹងវិទ្យាសាស្ត្រសង្គម និងសេដ្ឋកិច្ចនៃវិស័យវប្បធម៌ ព្រមទាំងផ្ទៀងផ្ទាត់ការប្រើប្រាស់បានល្អនូវបណ្តាលទ្ធផលទាំងនោះ
- វិភាគ និងកសាងផែនការអភិវឌ្ឍន៍វិស័យវប្បធម៌ រយៈពេលខ្លី មធ្យម និងវែង នឹងតាមដានការអនុវត្តនោះ
- រៀបចំ កសាងគោលនយោបាយយុទ្ធសាស្ត្រ និងកម្មវិធីអភិវឌ្ឍន៍វិស័យវប្បធម៌ និងកំណត់គោលដៅនៃការអភិវឌ្ឍនោះ
- សិក្សាពិចារណាលើវិធីសាស្ត្រធ្វើការងារក្នុងក្រសួង ព្រមទាំងលើកសំណើផ្សេងៗដើម្បីកែសម្រួល
- រៀបចំ កសាងកម្មវិធីវិនិយោគសាធារណៈ និងរៀបចំតម្រង់ទិសកម្មវិធីវិនិយោគឯកជន ក្នុងវិស័យវប្បធម៌
- រៀបចំ គម្រោងផែនការអំពីតម្រូវការចាំបាច់នានារបស់ក្រសួង ដើម្បីបញ្ចូលទៅក្នុងថវិការដ្ឋ និងសុំជំនួយឧបត្ថម្ភផ្សេងៗ
- សហការជាមួយក្រសួងផែនការ ដើម្បីរៀបចំប្រព័ន្ធស្ថិតិមួយ អំពីជីវភាពវប្បធម៌ទូទាំងប្រទេស
- រៀបចំ ចងក្រងកម្មវិធីវប្បធម៌ សម្រាប់ផ្សព្វផ្សាយតាមរយៈកម្មវិធីវិទ្យុ និងទូរទស្សន៍
- ធ្វើរបាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន
- ទទួលអនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន។

នាយកដ្ឋានផែនការ ស្ថិតិ និងសរុប ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់។

មាត្រា ១៦.-

នាយកដ្ឋានសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល មានភារកិច្ចដូចតទៅ ÷

- លើកកម្មវិធីនយោបាយ ស្តីពីវិស័យសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល

- អនុវត្តទូលំទូលាយនយោបាយសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ក្នុងគោលដៅជំរុញលើកទឹកចិត្តក្នុងការបង្កបង្កើតផលិតផលថ្មីខាងវិស័យវប្បធម៌

- គ្រប់គ្រងសម្របសម្រួលនិងធ្វើឱ្យប្រសើរឡើងនូវការអនុវត្តច្បាប់សិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល

- ជំរុញការបង្កើត ការណែនាំ និងការត្រួតពិនិត្យអង្គភាពគ្រប់គ្រងសិទ្ធិរួម

- អប់រំ និងផ្សព្វផ្សាយឱ្យមានការយល់ដឹងអំពីកម្មសិទ្ធិបញ្ញាផ្នែកសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល

- ធ្វើរបាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន

- ទទួលអនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន។

នាយកដ្ឋានសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់។

មាត្រា ១៧.-

នាយកដ្ឋាន សហប្រតិបត្តិការវប្បធម៌អន្តរជាតិ និងកិច្ចការអាស៊ាន មានភារកិច្ចដូចតទៅ ÷

- កសាងនិងគ្រប់គ្រងរាល់ឯកសារការងារសហប្រតិបត្តិការវប្បធម៌ជាមួយបណ្តាប្រទេសលើសកលលោក

- គ្រប់គ្រងខ្លឹមសារនៃកិច្ចព្រមព្រៀងលើវិស័យវប្បធម៌ និងវិចិត្រសិល្បៈ ជាមួយអន្តរជាតិ អាស៊ាន ដោយធ្វើការតាមដាន និងជំរុញការអនុវត្តឱ្យមានប្រសិទ្ធភាព

- វាយតម្លៃ និងរៀបចំកិច្ចព្រមព្រៀង កិច្ចសហប្រតិបត្តិការ ជាមួយបណ្តាប្រទេសលើសកលលោកពិសេសប្រទេសអាស៊ាន អំពីវិស័យវប្បធម៌

- សហការ និងសម្របសម្រួលជាមួយបណ្តាក្រសួង អង្គទូត អង្គការជាតិ និងអន្តរជាតិ សមាគមនានាដើម្បីរៀបចំខ្លឹមសារកិច្ចព្រមព្រៀង និងគម្រោងស្នើសុំជំនួយដែលពាក់ព័ន្ធនឹងវិស័យវប្បធម៌

- រៀបចំសម្រួលបែបបទជូនគណៈប្រតិភូ កម្មសិក្សាការីរបស់ក្រសួង ដែលចេញទៅបំពេញទស្សនកិច្ច ឬកម្មសិក្សា និងសកម្មភាពផ្លាស់ប្តូរវប្បធម៌ ជាមួយអន្តរជាតិ តាមការសម្រេចរបស់ប្រធានស្ថាប័ន

- ធ្វើរបាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន

- ទទួលអនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន។

នាយកដ្ឋានសហប្រតិបត្តិការវប្បធម៌អន្តរជាតិ និងកិច្ចការអាស៊ាន ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួន ជាជំនួយការតាមការចាំបាច់។

មាត្រា ១៨.-

សាលាបណ្តុះបណ្តាលក្របខ័ណ្ឌវប្បធម៌ មានភារកិច្ចដូចតទៅ ÷

- ធ្វើការបណ្តុះបណ្តាលនូវមុខវិជ្ជាជំនាញចាំបាច់ មុនបញ្ចូលជាក្របខ័ណ្ឌមន្ត្រីរាជការរបស់ក្រសួង
- រៀបចំធ្វើវិក្រឹតការ និងសុក្រឹតការមន្ត្រីរាជការរបស់ក្រសួង
- រៀបរៀងកម្មវិធីសិក្សាសមស្របតាម ការរៀបចំក្របខ័ណ្ឌមន្ត្រីរាជការរបស់ក្រសួង
- ធ្វើរបាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន
- ទទួលអនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន ។

សាលាបណ្តុះបណ្តាលក្របខ័ណ្ឌវប្បធម៌ ដឹកនាំដោយនាយកមួយរូប និងនាយករងមួយចំនួន ជាជំនួយការតាមការចាំបាច់ ។

ជំពូកទី ៧

អគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌

មាត្រា ១៩.-

អគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌ មានមុខងារអនុវត្តនូវរាល់បេសកកម្មរបស់ក្រសួង ក្នុងការប្រតិបត្តិនយោបាយលើ វិស័យអភិវឌ្ឍន៍វប្បធម៌ និងអប់រំសិល្បៈ ភាពយន្ត វីដេអូ និងពហុមេឌីយ៉ា សិល្បៈទស្សនីយភាព សិល្បៈសូនរូប និងសិល្បៈសិប្បកម្ម សៀវភៅ និងការអានសាធារណៈ ។

មាត្រា ២០.-

អគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌ ត្រូវបានដឹកនាំដោយអគ្គនាយកមួយរូប អមដោយអគ្គនាយករងមួយចំនួនជាជំនួយការ តាមការចាំបាច់ ។

អគ្គនាយកដ្ឋាន បច្ចេកទេសវប្បធម៌ មាននាយកដ្ឋានចំណុះចំនួន ៥ (ប្រាំ) :

១. នាយកដ្ឋាន អភិវឌ្ឍន៍វប្បធម៌
២. នាយកដ្ឋាន សិល្បៈភាពយន្ត និងផ្សព្វផ្សាយវប្បធម៌
៣. នាយកដ្ឋាន សិល្បៈទស្សនីយភាព
៤. នាយកដ្ឋាន សិល្បៈសូនរូប និងសិល្បៈសិប្បកម្ម
៥. នាយកដ្ឋាន សៀវភៅ និងការអាន ។

មាត្រា ២១.-

នាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌ មានភារកិច្ចដូចតទៅ ÷

- លើកទឹកចិត្តរាល់សកម្មភាពវប្បធម៌ ព្រមទាំងរៀបចំចាត់តាំងបណ្តាការសម្តែងសិល្បៈវប្បធម៌ ពិពណ៌ សំដៅធ្វើឱ្យមហាជនចាប់អារម្មណ៍និងវប្បធម៌របស់ខ្លួន
- បំផុសនិងសម្រួលដល់សមាគមវិជ្ជាជីវៈផ្សេងៗក្នុងវិស័យវប្បធម៌ សំដៅលើកកម្ពស់មនសិការវិជ្ជាជីវៈ ព្រមទាំងការពារផលប្រយោជន៍ស្របច្បាប់របស់គេ

- លើកទឹកចិត្ត និងត្រួតពិនិត្យចំពោះការថែរក្សារាល់សកម្មភាពវប្បធម៌ល្អៗរបស់ប្រជាពលរដ្ឋ តាមតំបន់ទូទាំងប្រទេស
- ធ្វើរបាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន
- ទទួលអនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន។

នាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌ ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់។

មាត្រា ២២.-

នាយកដ្ឋានសិល្បៈភាពយន្ត និងផ្សព្វផ្សាយវប្បធម៌ មានភារកិច្ចដូចតទៅ ÷

- តម្រង់ទិស និងលើកទឹកចិត្ត ក្នុងការផ្សព្វផ្សាយវប្បធម៌ និងសិល្បៈ តាមរយៈភាពយន្ត វីដេអូ និងពហុមេឌីយ៉ា
- សិក្សា និងអនុញ្ញាត ការធ្វើអាជីវកម្មសិល្បៈទី ៧ ក្នុងរូបភាពជាភាពយន្ត និង វីដេអូ
- រក្សាឯកសារភាពយន្ត និងវីដេអូជាតិ
- អនុញ្ញាត និងលើកទឹកចិត្តធ្វើឱ្យអភិវឌ្ឍសិល្បៈទី ៧ ក្នុងរូបភាពជាភាពយន្ត និងវីដេអូ
- ផលិត ផ្សព្វផ្សាយ គ្រប់គ្រង និងត្រួតពិនិត្យវិស័យវប្បធម៌តាមរូបភាព ភាពយន្ត វីដេអូ និងពហុមេឌីយ៉ា ដោយសហការជាមួយក្រសួងពាក់ព័ន្ធ
- បណ្តុះបណ្តាល បំពាក់បំប៉ន មុខជំនាញភាពយន្ត និងវីដេអូ
- ធ្វើរបាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន
- ទទួលអនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន។

នាយកដ្ឋានសិល្បៈភាពយន្ត និងផ្សព្វផ្សាយវប្បធម៌ ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់។

មាត្រា ២៣.-

នាយកដ្ឋាន សិល្បៈទស្សនីយភាព មានភារកិច្ចដូចតទៅ ÷

- លើកទឹកចិត្តការបង្កើតស្នាដៃធ្វើឱ្យសម្បូរបែបព្រមទាំងផ្សព្វផ្សាយយ៉ាងទូលំទូលាយនូវទស្សនីយភាពរស់មានវិស័យ ល្ខោន អាយ៉ៃ ចាប៉ីដងវែង យីកេ តន្ត្រី របាំ សៀក និងទស្សនីយភាពប្រជាប្រិយប្លែកៗផ្សេងទៀត
- កំណត់នូវនយោបាយវិមជ្ឈការ អំពីជំនាញសិល្បៈចំពោះបណ្តាក្រុមសិល្បៈតាមខេត្ត-ក្រុងទូទាំងប្រទេស
- សហការជាមួយសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ក្នុងការបណ្តុះបណ្តាលសិល្បករនៃវិស័យសិល្បៈរស់
- លើកឡើងនូវនយោបាយ អំពីការពិចារណា និងការកែសម្រួលបណ្តាវិជ្ជាជីវៈនិងការរួមរៀបវិស័យសិល្បៈ
- សិក្សាអំពីសកម្មភាពទាំងឡាយ សំដៅពង្រីកទស្សនិកជន
- ធ្វើរបាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន

- ទទួលអនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន ។

នាយកដ្ឋានសិល្បៈទស្សនីយភាព ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួន ជាជំនួយការតាមការចាំបាច់ ។

មាត្រា ២៤.-

នាយកដ្ឋានសិល្បៈសូនរូប និងសិល្បៈសិប្បកម្ម មានភារកិច្ចដូចតទៅ ÷

- ណែនាំ និងគ្រប់គ្រង លើគោលការណ៍ជំនាញ ដើម្បីពង្រឹងគុណភាពដល់ បណ្តាសមាគម អ្នកបង្កើត ស្នាដៃ អាជីវករ សេវាករ សិល្បៈសូនរូប និងសិល្បៈសិប្បកម្ម ស្របតាមបេសកកម្មរបស់ក្រសួង
- ចងក្រងឯកសារសិល្បៈសូនរូប និងសិល្បៈសិប្បកម្ម ដើម្បីទុកជាក្បូនខ្នាតសម្រាប់កំណត់បទដ្ឋានបច្ចេកទេស
- បង្កើតកម្មវិធីបណ្តុះបណ្តាល និងផ្សព្វផ្សាយវិជ្ជាជីវៈសិល្បៈសូនរូប និងសិល្បៈសិប្បកម្ម ជូនដល់មហាជនដែលមានវិជ្ជាជីវៈសិល្បៈសូនរូប និងសិល្បៈសិប្បកម្ម
- តម្រង់ទិសបំផុសការបង្កើតស្នាដៃ និងលើកទឹកចិត្តដល់អ្នកបង្កើតស្នាដៃ ព្រមទាំងផ្សព្វផ្សាយក្នុងចំណោមមហាជន នូវរាល់រូបភាពសិល្បៈសូនរូប និងសិល្បៈសិប្បកម្ម
- ធ្វើរបាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន
- ទទួលអនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន ។

នាយកដ្ឋានសិល្បៈសូនរូប និងសិល្បៈសិប្បកម្ម ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់ ។

មាត្រា ២៥.-

នាយកដ្ឋានសៀវភៅ និងការអាន មានភារកិច្ចដូចតទៅ ÷

- ថែរក្សា ការពារ និងលើកតម្កើងរាល់ស្នាដៃសរសេរ ដែលបានរក្សាទុក និងតម្កល់ទុកតាមច្បាប់
- ទ្រទ្រង់ចំពោះសៀវភៅគ្រប់ប្រភេទ បង្កលក្ខណៈងាយស្រួលក្នុងការបង្កើតចេញជាសៀវភៅ និងជួយគាំពារចំពោះការផ្សព្វផ្សាយ
- ធ្វើឱ្យសៀវភៅទៅដល់មនុស្សគ្រប់រូប តាមរយៈការអានជាសាធារណៈ
- គ្រប់គ្រងបណ្ណាល័យជាតិ និងបណ្ណាល័យនៅតាមខេត្ត-ក្រុង
- អនុញ្ញាតឱ្យបើក និងត្រួតពិនិត្យបណ្ណាគារគ្រប់ប្រភេទ
- ធ្វើរបាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន
- ទទួលអនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន ។

នាយកដ្ឋានសៀវភៅ និងការអាន ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួន ជាជំនួយការតាមការចាំបាច់ ។

ជំពូកទី ៨
អគ្គនាយកដ្ឋានបេតិកភណ្ឌ

មាត្រា ២៦.-

អគ្គនាយកដ្ឋានបេតិកភណ្ឌ មានមុខងារអនុវត្តរាល់បេសកកម្មរបស់ក្រសួង ក្នុងប្រតិបត្តិការនយោបាយលើផ្នែកបេតិកភណ្ឌ សារមន្ទីរ គាំពារ និងអភិរក្សសំណង់បុរាណ និងវត្ថុបុរាណ ការស្រាវជ្រាវ រុករក និងកំណាយស្ថានីយបុរេប្រវត្តិ ប្រវត្តិសាស្ត្រដែលកប់ក្នុងដី ក្រោមទឹក និងការអប់រំផ្សព្វផ្សាយ ។

មាត្រា ២៧.-

អគ្គនាយកដ្ឋានបេតិកភណ្ឌ ត្រូវបានដឹកនាំដោយអគ្គនាយកមួយរូប អមដោយអគ្គនាយករងមួយចំនួនជាជំនួយការតាមការចាំបាច់ ។

អគ្គនាយកដ្ឋានបេតិកភណ្ឌ មាននាយកដ្ឋានចំណុះចំនួន ៤ (បួន) :

១-នាយកដ្ឋាន បុរាណវត្ថុ

២-នាយកដ្ឋាន សារមន្ទីរ

៣-នាយកដ្ឋាន គាំពារ និងអភិរក្សសំណង់បុរាណ

៤-នាយកដ្ឋាន បុរាណវិទ្យា បុរេប្រវត្តិវិទ្យា ។

មាត្រា ២៨.-

នាយកដ្ឋាន បុរាណវត្ថុ មានភារកិច្ចដូចតទៅ÷

- គ្រប់គ្រង និងអភិរក្សរាល់បុរាណវត្ថុផ្សេងៗដែលមានតម្លៃជាប្រវត្តិសាស្ត្រ សិល្បៈ សាសនា ឬវិទ្យាសាស្ត្រ ហើយដែលកិច្ចការពារ រាល់ចលនសម្បត្តិវប្បធម៌ទាំងឡាយនោះបម្រើឱ្យប្រយោជន៍សាធារណៈ
- រៀបចំចងក្រងលិខិតបទដ្ឋានផ្សេងៗ ដើម្បីធានាដល់ការការពារបុរាណវត្ថុ និងត្រួតពិនិត្យលើការនាំចេញនាំចូល វត្ថុសិល្បៈផ្សេងៗ ដើម្បីទប់ស្កាត់ចរាចរសម្បត្តិវប្បធម៌ខុសច្បាប់
- រៀបចំ និងផ្តល់អាជ្ញាប័ណ្ណ សម្រាប់ការសុំអនុញ្ញាតនាំចេញ នាំចូល វត្ថុសិល្បៈផ្សេងៗ
- ចុះអប់រំ និងផ្សព្វផ្សាយ ដល់សាធារណជន អំពីច្បាប់ការពារបេតិកភណ្ឌវប្បធម៌ និងលិខិតបទដ្ឋានផ្សេងៗដែលមានទិសដៅថែរក្សា និងការពារឱ្យបានគង់វង្សនូវសម្បត្តិវប្បធម៌ជាតិ
- ទទួលអនុវត្តសិទ្ធិស្នើសុំ ឬប្តឹងទាមទារឱ្យធ្វើការបញ្ជូនត្រឡប់មកប្រទេសកម្ពុជាវិញ នូវបុរាណវត្ថុទាំងឡាយណាដែលត្រូវបានគេនាំចេញ ឬធ្វើនីហរណកម្មដោយខុសច្បាប់
- ធ្វើរបាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន
- ទទួលអនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន ។

នាយកដ្ឋាន បុរាណវត្ថុ ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

មាត្រា ២៩.-

នាយកដ្ឋាន សារមន្ទីរ មានភារកិច្ចដូចតទៅ ÷

- គ្រប់គ្រងការអភិរក្ស ការថែរក្សា ការជួសជុល ការសិក្សា និងការធ្វើឱ្យសំបូរបែបនៃសមុច្ច័យសាធារណៈ
- ធានាការផ្សព្វផ្សាយ និងការតាំងបង្ហាញសមុច្ច័យទាំងឡាយចំពោះសាធារណៈជន ព្រមទាំងត្រួតពិនិត្យតាមលក្ខណៈវិទ្យាសាស្ត្របច្ចេកទេស បណ្តាសមុច្ច័យទាំងនោះ
- គ្រប់គ្រងលើសារមន្ទីររដ្ឋ និងសារមន្ទីរគ្រប់ប្រភេទនៅទូទាំងប្រទេស
- ធ្វើរបាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន
- ទទួលអនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន។

នាយកដ្ឋានសារមន្ទីរ ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់។

មាត្រា ៣០.-

នាយកដ្ឋាន គាំពារ និងអភិរក្សសំណង់បុរាណ មានភារកិច្ចដូចតទៅ ÷

- ធ្វើបញ្ជី និងធ្វើចំណាត់ថ្នាក់ប្រាសាទបុរាណ រមណីយដ្ឋានវប្បធម៌ និងសំណង់បុរាណផ្សេងៗទៀត ដែលមាននៅតាមខេត្ត-ក្រុងនានា ដោយសហការយ៉ាងជិតស្និទ្ធជាមួយមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈខេត្ត-ក្រុង ដើម្បីរៀបចំទុកជាឯកសារ
- គ្រប់គ្រង និងសិក្សាស្រាវជ្រាវ ដើម្បីអនុវត្តកិច្ចការការពារបេតិកភណ្ឌវប្បធម៌ ដូចមានចែងនៅក្នុងច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ជាតិ
- រៀបចំ ស្ថាបនាអភិរក្សដ្ឋាន នៅតាមបណ្តាក្រុមប្រាសាទ និងរមណីយដ្ឋានវប្បធម៌នានា ដោយមានអភិរក្សករ និងអ្នកជំនាញផ្សេងៗធ្វើការនៅទីនោះ
- សិក្សាស្រាវជ្រាវ និងចងក្រងជាឯកសារប្រវត្តិសាស្ត្រ និងវិទ្យាសាស្ត្រ នូវបណ្តាប្រាសាទបុរាណ រមណីយដ្ឋានវប្បធម៌ និងសំណង់បុរាណ ដែលទើបរកឃើញថ្មីពុំទាន់បោះពុម្ពផ្សព្វផ្សាយ
- ធ្វើរបាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន
- ទទួលអនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន។

នាយកដ្ឋានគាំពារ និងអភិរក្សសំណង់បុរាណ ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួន ជាជំនួយការ តាមការចាំបាច់។

មាត្រា ៣១.-

នាយកដ្ឋានបុរាណវិទ្យា និងបុរេប្រវត្តិវិទ្យា មានភារកិច្ចដូចតទៅ ៖

- ស្រាវជ្រាវ រុករកកំណត់ទីតាំង និងចុះបញ្ជីទីតាំងនៃស្ថានីយបុរេប្រវត្តិ និងប្រវត្តិសាស្ត្រ ដែលកប់ក្នុងដី និងក្រោមទឹក
- ធ្វើកំណាយស្របច្បាប់លើស្ថានីយមួយចំនួន ដែលមានសារៈសំខាន់ក្នុងការយល់ដឹងពី សង្គម និងវប្បធម៌សម័យបុរាណ
- ធ្វើការវិភាគរាល់វត្ថុបុរាណ ដែលជីកបានពីស្ថានីយដែលមានប្រភពច្បាស់លាស់
- ផ្សព្វផ្សាយនូវព័ត៌មាន ដែលស្រាវជ្រាវរកឃើញ ពីកំណាយស្របច្បាប់ ដើម្បីចែករំលែកចំណេះដឹងដល់មន្ត្រីក្រសួង និងបញ្ញវន្តទូទៅ
- ធ្វើរបាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន
- ទទួលអនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន ។

នាយកដ្ឋានបុរាណវិទ្យា និងបុរេប្រវត្តិវិទ្យា ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួន ជាជំនួយការតាមការចាំបាច់ ។

ជំពូកទី ៩
សាលាមធ្យមវិចិត្រសិល្បៈ

មាត្រា ៣២.-

សាលាមធ្យមវិចិត្រសិល្បៈ មានភារកិច្ចដូចតទៅ ៖

- ជ្រើសរើសសិស្សតាមឧបនិស្ស័យឱ្យចូលសិក្សា និងប្រឡងបញ្ចប់ដោយផ្តល់នូវសញ្ញាប័ត្រសិល្បៈ និងស្នាតកប័ត្រសិល្បៈ
- បណ្តុះបណ្តាលធនធានមនុស្សចាប់តាំងពីកម្រិតបឋម ដល់មធ្យម ដើម្បីឱ្យក្លាយជាអ្នកជំនាញសិល្បៈ ទាំងទ្រឹស្តី ទាំងការអនុវត្ត និងការបង្កើតថ្មីតាមការចាំបាច់របស់សង្គម
- បំពាក់បំប៉នមន្ត្រីជំនាញ និងសិល្បករ ឱ្យក្លាយជាគ្រូបង្ហាត់ ដែលមានគុណសម្បត្តិសិល្បៈ និងវិជ្ជាជីវៈពេញលេញ
- ស្រាវជ្រាវចងក្រងកម្មវិធីសិក្សា និងវិធីសាស្ត្របង្រៀនទុកជាឯកសារបច្ចេកទេសសិល្បៈ
- សម្របសម្រួលកម្មវិធីសិក្សាជាមួយ សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ និងសហការជាមួយអង្គការជាតិ និងអន្តរជាតិ លើមូលដ្ឋានការងារបណ្តុះបណ្តាល និងស្រាវជ្រាវបច្ចេកទេសសិល្បៈ ដើម្បីធ្វើការឱ្យកាន់តែប្រសើរឡើងនូវការអប់រំសិល្បៈ
- ធ្វើរបាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន
- ទទួលអនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន ។

មាត្រា ៣៣.-

សាលាមធ្យមវិចិត្រសិល្បៈ ដឹកនាំដោយនាយកសាលាមួយរូប មានឋានៈស្មើប្រធាននាយកដ្ឋាន និងនាយករងមួយចំនួន មានឋានៈស្មើអនុប្រធាននាយកដ្ឋានជាជំនួយការ តាមការចាំបាច់។

សាលាមធ្យមវិចិត្រសិល្បៈ អាចបង្កើតសាលាឯកទេសសិល្បៈផ្សេងៗ ទៅតាមការរីកចម្រើន និងតម្រូវការចំពោះមុខរបស់សង្គមជាតិ។

ជំពូកទី ១០

អង្គភាពមូលដ្ឋាន

មាត្រា ៣៤.-

នៅតាម ខេត្ត-ក្រុងនីមួយៗ មានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត-ក្រុងមួយដែលទទួលបន្ទុកអនុវត្ត និងសម្របសម្រួលសកម្មភាពរបស់ក្រសួង។ នៅតាមស្រុក-ខ័ណ្ឌនីមួយៗ មានការិយាល័យវប្បធម៌ និងវិចិត្រសិល្បៈស្រុក-ខ័ណ្ឌ ដែលទទួលបន្ទុកអនុវត្ត និងសម្របសម្រួលសកម្មភាពរបស់មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត-ក្រុង។

ជំពូកទី ១១

គ្រឹះស្ថានសាធារណៈ

មាត្រា ៣៥.-

អង្គភាពដែលស្ថិតនៅមាត្រា ៤ ចំណុច គ នៃអនុក្រឹត្យនេះ ត្រូវបាននិងរៀបចំឱ្យទៅជាគ្រឹះស្ថានសាធារណៈ ឧបនិស្ស័យ រដ្ឋបាល ក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។ការរៀបចំ និងការប្រព្រឹត្តទៅរបស់គ្រឹះស្ថានសាធារណៈ ត្រូវកំណត់ដោយអនុក្រឹត្យ ដែលមានលក្ខន្តិកៈមួយដោយឡែករបស់ខ្លួន ដោយអនុវត្តស្របតាមព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល។

ជំពូកទី ១២

អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

មាត្រា ៣៦.-

អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុត្រូវបានបង្កើតឡើងដោយ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមល័ក្ខខ័ណ្ឌនៃបទបញ្ញាកំណត់ក្នុងអនុក្រឹត្យលេខ ៨១ ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតស្ថាប័នត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិកាក្នុងបណ្តាក្រសួង។

ជំពូកទី ១៣

អវសានប្បញ្ញត្តិ

មាត្រា ៣៧.-

បទប្បញ្ញត្តិនៃអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ១៩៩៧ និងបទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយ នឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

មាត្រា ៣៨.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ២៨ អនក្រ.បក. ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៧

អង្គការលេខរបស់ ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៤០៣ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ
រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ អភិបាលខេត្តកណ្តាល

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន០៥រូប ដែលបានបរិច្ចាគកម្លាំងកាយ-ចិត្ត និងធនធានជួយកសាងអគារសិក្សា អណ្តូងទឹក បង្គន់អនាម័យ ខ្លោងទ្វារ និងផ្តល់សម្ភារៈសិក្សា ជូនប្រជាពលរដ្ឋ ភូមិព្រៃធំ ឃុំសន្លុង ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ដូចមានរាយនាមខាងក្រោម :-

១-លោក SAKAMOTO សប្បុរសជននៅប្រទេសជប៉ុន ថវិកាចំនួន ១០.៥០០ ដុល្លារ
២-លោកស្រី SAKAMOTO SUNAO សប្បុរសជននៅប្រទេសជប៉ុន ថវិកាចំនួន ១០.៣០០ ដុល្លារ
៣-លោកស្រី SAGATA NORIYOSHI សប្បុរសជននៅប្រទេសជប៉ុន ថវិកាចំនួន ១០.២០០ ដុល្លារ
៤-លោក **អ៊ិត វិជ័យ** សប្បុរសជនខ្មែរនៅប្រទេសជប៉ុន ថវិកាចំនួន ១០.០០០ ដុល្លារ
៥-លោក **ចែម ចិរសុទ្ធ** ទំនាក់ទំនងសប្បុរសជនជប៉ុនឲ្យជួយកសាងអគារសិក្សាបាន ចំនួន ០៦ខ្នង

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។ ៩ៗ

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ឆ្នាំ ២០០៧

ហ៊ុន សែន

កន្លែងទទួល :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២០៤ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលខេត្តកណ្តាល

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន០២រូប ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួន ជួយសាងសង់អគារសុខាភិបាល ចំនួន ០១ខ្នង បំពាក់ដោយបរិក្ខារ និងថ្នាំពេទ្យគ្រប់ប្រភេទ ព្រមទាំងផ្តល់ម៉ាស៊ីនភ្លើង អណ្តូងទឹក និងអាងទឹក នៅប៉ុស្តិ៍សុខភាព ឃុំស៊ីធរ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ដូចមានរាយនាមខាងក្រោម :-

៦) ការបែងចែកភាគហ៊ុន និងសិទ្ធិបោះឆ្នោត កិច្ចព្រមព្រៀងផ្សេងៗរវាងភាគទុនិកក្នុងគោលបំណងតម្រង់ទិសគោលនយោបាយរបស់ក្រុមហ៊ុនធានារ៉ាប់រង។

៧) ភាគទុនិកដែលមានសិទ្ធិបោះឆ្នោតចាប់ពីដប់ (១០)ភាគរយឡើងទៅ ត្រូវផ្តល់ពត៌មានដែលមានរៀបរាប់នៅក្នុងប្រការ ៥ នៃប្រកាសនេះ។

៨) អត្តសញ្ញាណរបស់បុគ្គល (យ៉ាងតិចពីររូប) ដែលទទួលខុសត្រូវលើដំណើរការអាជីវកម្មធានារ៉ាប់រង ឬការគ្រប់គ្រងមុខងារសំខាន់ៗ (ដូចជា មុខងារលក់ សំណង វាយតម្លៃហានិភ័យ និងគណនេយ្យ)។ អ្នកគ្រប់គ្រងទាំងនេះ ត្រូវផ្តល់ពត៌មានដែលមានចែងនៅក្នុងប្រការ៦ នៃប្រកាសនេះ ហើយប្រធានសាខារបស់ក្រុមហ៊ុនធានារ៉ាប់រងបរទេសនៅកម្ពុជា ត្រូវតែងតាំងដោយអ្នកគ្រប់គ្រងដែលមានសមត្ថកិច្ចនៃទីស្នាក់ការកណ្តាល។

៩) អត្តសញ្ញាណរបស់សមាជិក ដែលមានសិទ្ធិធ្វើការសម្រេចចិត្ត និង ពត៌មានដែលតម្រូវនៅក្នុងប្រការ ៦ នៃប្រកាសនេះ។

១០) ប្រសិនបើអ្នកដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណ គឺជានីតិបុគ្គល ដែលបានបង្កើតរួចមកហើយ ត្រូវផ្តល់ការពិពណ៌នាអំពីអាជីវកម្មរបស់ខ្លួន និងថតចម្លងរបាយការណ៍ហិរញ្ញវត្ថុសវនកម្មបី (៣) ឆ្នាំចុងក្រោយ ។

ខ- ផែនការអាជីវកម្ម

ការពិពណ៌នាអំពីផែនការសកម្មភាពសម្រាប់រយៈពេលបី (៣)ឆ្នាំ បន្តបន្ទាប់ :

១) ប្រភេទ និងទំហំនៃសេវាដែលបានធានារ៉ាប់រង និងការប៉ាន់ប្រមាណអំពីតម្រូវការធានារ៉ាប់រងបន្ត។

២) ប្រភេទ និង ទំហំនៃសេវាដែលផ្តល់ចំពោះអតិថិជនផ្សេងទៀត ដូចជា ការគ្រប់គ្រងហានិភ័យ ការបង្ការការខូចខាតជាដើម។

៣) ប្រភេទអតិថិជន (បុគ្គល ក្រុមហ៊ុន អង្គការអន្តរជាតិ) ដែលក្រុមហ៊ុនធានារ៉ាប់រងចង់បាន។

៤) ប្រភេទធនធានហិរញ្ញវត្ថុគ្រោងទុក ដែលអាចជាមូលនិធិផ្ទាល់ខ្លួន បុរេប្រទានរបស់ភាគទុនិក ឥណទានធនាគារ ឬ ឥណទានផ្សេងទៀត។

៥) ចំណាយអភិវឌ្ឍន៍សម្រាប់បង្កើតក្រុមហ៊ុន។

៦) ចំនួនបុគ្គលិកសម្រាប់រយៈពេលបី (៣)ឆ្នាំ បន្តបន្ទាប់ ដោយផ្តល់ព័ត៌មានលំអិតអំពីប្រភេទបុគ្គលិក។

៧) ចំនួន និងទីតាំងនៃការិយាល័យសាខា នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៨) តារាងតុល្យការ និងរបាយការណ៍លទ្ធផលព្យាករណ៍សម្រាប់ការិយបរិច្ឆេទបី (៣)ឆ្នាំបន្តបន្ទាប់។

គ- សវនកម្មផ្ទៃក្នុង

១) រចនាសម្ព័ន្ធសវនកម្មផ្ទៃក្នុងដែលមានស្រាប់ និងគ្រោងទុក ដើម្បីធានាដល់ការបំពេញលក្ខខណ្ឌដែលតម្រូវដោយបទប្បញ្ញត្តិហិរញ្ញវត្ថុ។

២) វិធីសាស្រ្តក្នុងការដាក់កម្រិតលើប្រភេទហានិភ័យនីមួយៗ និង នីតិវិធីដែលបានគ្រោងទុក ដើម្បីធានាដល់ការប្រព្រឹត្តតាមច្បាប់ រួមទាំងការដាក់កម្រិតសិទ្ធិអំណាចរបស់ភ្នាក់ងារ។

៣) នីតិវិធីដែលបានគ្រោងទុក ដើម្បីបង្កើត និងធានាផលស្តង់ដាក្រមសីលធម៌វិជ្ជាជីវៈដែលទាក់ទងនឹងសកម្មភាពលក់ និងការប្រកួតប្រជែងស្មើភាព។

៤) សមាសភាព និង ភារៈកិច្ចរបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង។

ឃ- សវនកម្មឯករាជ្យ

១) អត្តសញ្ញាណរបស់សវនករដែលបានស្នើឡើងត្រូវមាននៅក្នុងបញ្ជីឬត្រូវបញ្ចូលក្នុងបញ្ជីសវនករឯករាជ្យរបស់ក្រុមហ៊ុនធានារ៉ាប់រង។

២) ប្រភេទនៃការងាររបស់សវនករ។

ង- គំរូបណ្ណសន្យាធានារ៉ាប់រង

គំរូបណ្ណសន្យារ៉ាប់រង និងបណ្ណផ្សព្វផ្សាយដែលនឹងប្រើប្រាស់។

ច- លក្ខខណ្ឌបន្ថែមសម្រាប់សាខា ឬ បុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនធានារ៉ាប់រងបរទេស

១) ការពិពណ៌នាអំពីនីតិវិធីសម្រាប់ការត្រួតពិនិត្យរបស់ក្រុមហ៊ុនមេ លើសាខា ឬលើបុត្រសម្ព័ន្ធបរទេស។

២) ការពិពណ៌នាអំពីការគ្រប់គ្រងលើសាខា ឬបុត្រសម្ព័ន្ធបរទេស ដោយអាជ្ញាធរមានសមត្ថកិច្ចនៅក្នុងប្រទេសដើម។

៣) តារាងតុល្យការ និងរបាយការណ៍លទ្ធផលសវនកម្ម សម្រាប់រយៈពេលបី(៣)ឆ្នាំចុងក្រោយ។

៤) របាយការណ៍ហិរញ្ញវត្ថុសវនកម្មសម្រាប់រយៈពេលបីឆ្នាំដែលបានបញ្ជាក់ដោយសវនករឯករាជ្យនៃប្រទេសដើម។

៥) ការបង្ហាញពីទីតាំងនៃសាខាដែលក្រុមហ៊ុនមានបំណងបង្កើតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៦) លិខិតផ្តល់សិទ្ធិ ដែលបានបកប្រែស្តីពីការធ្វើអាជីវកម្មនៅក្នុងប្រទេសដើម។

៧) ពតិមាន និងលិខិតអនុញ្ញាតពីនិយ័តករនៃប្រទេសដើមដែលបញ្ជាក់ថា ក្រុមហ៊ុនធានារ៉ាប់រងមានលទ្ធភាពទូទាត់សំណង និងបំពេញបានតាមលក្ខខណ្ឌរបស់និយ័តករ នៃប្រទេសដើមជាភាសាខ្មែរ។

៨) លិខិតតែងតាំងនីតិបុគ្គល ឬរូបវន្តបុគ្គលដែលមានលក្ខណៈវិនិច្ឆ័យសមស្រប ក្នុងការគ្រប់គ្រងសាខានៅក្នុងប្រទេសកម្ពុជា។

៩) លក្ខខណ្ឌពតិមាននៅក្នុងប្រការ ៦ ព្រមទាំងជីវប្រវត្តិសង្ខេប និង លិខិតថ្កោលទោសពីប្រទេសដើមរបស់បុគ្គលទាំងឡាយ ដែលនឹងមកគ្រប់គ្រងការិយាល័យសាខាណាមួយ។

១០) ឯកសារផ្សេងទៀតដែលតម្រូវដោយនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ប្រការ ៩: ភាគទុនិកដែលកាន់កាប់ដើមទុន ឬសិទ្ធិបោះឆ្នោតចាប់ពីដប់ (១០)ភាគរយឡើងទៅ ត្រូវផ្តល់

ពត៌មានដូចខាងក្រោមនេះ :

ក- អត្តសញ្ញាណរបស់ភាគទុនិក

១) ក្នុងករណីជានីតិបុគ្គល : បង្ហាញឈ្មោះ ទម្រង់គតិយុត្តិ និងអាស័យដ្ឋាននៃទីស្នាក់ការកណ្តាល។

២) ក្នុងករណីជារូបវន្តបុគ្គល នាមត្រកូលនិងនាមខ្លួន ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើត សញ្ជាតិ (ឬ សញ្ជាតិទីពីរ ប្រសិនបើមាន) និងអាស័យដ្ឋាននៃប្រទេសដើម ។

៣) រាល់ភាគទុនិក ឬ អគ្គនាយកនៃនីតិបុគ្គល ត្រូវផ្តល់ជីវប្រវត្តិសង្ខេប និងបំពេញព៌ត៌មាន ដែលមានចែងនៅក្នុងប្រការ ៦។

ខ- បង្ហាញចំនួន ឬ ភាគរយនៃការចូលរួមទុន ឬសិទ្ធិបោះឆ្នោតសមមូលៈ ពិពណ៌នាកិច្ចព្រមព្រៀងគតិយុត្តិ និងហិរញ្ញវត្ថុនៃការទិញមូលប័ត្រទាំងនោះ ។ ប្រសិនបើភាគទុនិក គឺជារូបវន្តបុគ្គលត្រូវបញ្ជាក់ពីប្រភពនៃដើមទុនដែលយកមកទិញមូលប័ត្រនោះ ។ បញ្ជាក់ថា តើការទិញលក់មូលប័ត្រនោះ ធ្វើឡើងត្រឹមត្រូវតាមទម្រង់ច្បាប់ឬបទប្បញ្ញត្តិឬទេដូចជា ទម្រង់ច្បាប់ដែលទាក់ទងនឹងការវិនិយោគបរទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

គ- បង្ហាញពីការបែងចែកភាគហ៊ុនរបស់ភាគទុនិកៈ ប្រសិនបើមាន គួរបញ្ជាក់ពីការបែងចែកភាគហ៊ុនរបស់ក្រុមហ៊ុនមេ និងក្រុមហ៊ុនភាគទុនិកហើយផ្តល់ ព៌ត៌មានអំពីភាគរយនៃភាគហ៊ុន និងសិទ្ធិបោះឆ្នោត។ ផ្តល់បញ្ជីឈ្មោះនៃអគ្គនាយក និងអ្នកគ្រប់គ្រង ផ្សេងទៀតរបស់ភាគទុនិក។

ឃ- ពិពណ៌នាសកម្មភាពរបស់ភាគទុនិកៈ ប្រសិនបើភាគទុនិក គឺជាផ្នែកមួយនៃសម្ព័ន្ធក្រុមហ៊ុនសូមផ្តល់ការពិពណ៌នាអំពីក្រុបហ៊ុនសំខាន់ៗនៃសម្ព័ន្ធនោះ ព្រមទាំងរចនាសម្ព័ន្ធផ្សេងៗ ។ បង្ហាញថា តើភាគទុនិកមានភាគហ៊ុននៅក្រុមហ៊ុនធានារ៉ាប់រង ឬក្នុងស្ថាប័នធនាគារផ្សេងទៀតឬទេ ។ បង្ហាញថាតើសម្ព័ន្ធក្រុមហ៊ុនមានភាគហ៊ុននៅក្នុង ក្រុមហ៊ុនធានារ៉ាប់រង ឬស្ថាប័ន ធនាគារឬទេ ហើយបើមានសូមបញ្ជាក់ពីភាគហ៊ុនទាំងនោះ។

ង- បង្ហាញថាតើភាគទុនិករូបនោះ និងក្រុមហ៊ុនដែលអាចពាក់ព័ន្ធទាំងឡាយ ធ្វើអាជីវកម្មធានារ៉ាប់រង និង ធនាគារឬទេ ហើយបើដូច្នោះមែន បង្ហាញពីបទប្បញ្ញត្តិ និងអាជ្ញាធរទាំងឡាយដែលពាក់ព័ន្ធ ។

ប្រការ ៦ : បុគ្គលនីមួយៗដែលបានកំណត់ក្នុងប្រការ ៤ និងជាអ្នកកាន់តំណែងគ្រប់គ្រង ដូចមានចែងនៅក្នុងប្រការ ៥ ត្រូវផ្តល់ព៌ត៌មាន ជីវប្រវត្តិសង្ខេប និងកម្រងសំណួរ ដូចខាងក្រោមនេះ :

ក- អត្តសញ្ញាណរបស់អ្នកគ្រប់គ្រង

១) នាមត្រកូល និងនាមខ្លួន ។

២) ថ្ងៃខែឆ្នាំ និង ទីកន្លែងកំណើត ។

៣) សញ្ជាតិ ។

៤) អាស័យដ្ឋានរបស់បុគ្គល(ទីកន្លែងស្នាក់នៅ បន្ទាប់ពីទទួលការតែងតាំងនិង ក្នុងករណីមានអាស័យដ្ឋានខុសគ្នា អ្នកគ្រប់គ្រងគួរតែស្នាក់នៅទីកន្លែងធ្វើអាជីវកម្មដូចជា នៅក្នុងប្រទេស

កម្ពុជា ជាដើម) ។

ខ- ប្រវត្តិនៃការសិក្សា និង បទពិសោធន៍

១) កម្រិតវប្បធម៌ ព្រមទាំង ថ្ងៃខែឆ្នាំ និងទីកន្លែងទទួលសញ្ញាប័ត្រ ។

២) បទពិសោធន៍ការងារក្នុងរយៈពេលដប់(១០)ឆ្នាំចុងក្រោយរួមទាំង ឈ្មោះ ទីកន្លែង និងសកម្មភាពអាជីវកម្មរបស់និយោជក ប្រភេទបទពិសោធន៍ដែលទទួលបាននិងទំហំនៃការទទួលខុសត្រូវ។

គ- បង្ហាញថាតើ ក្នុងការអនុវត្តន៍ភារកិច្ច លោកអ្នកនឹងគោរពតាមការណែនាំរបស់បុគ្គល ឬក្រុមហ៊ុនផ្សេងក្រៅពីអ្នកស្នើសុំអាជ្ញាប័ណ្ណឬទេ ដែលក្នុងករណីណាក៏ដោយ សូមផ្តល់ពត៌មានដែលពាក់ព័ន្ធទាំងអស់ ។

ឃ- ពិពណ៌នារាល់កិច្ចការគ្រប់គ្រងដែលលោកអ្នកនឹងទទួលខុសត្រូវដោយផ្ទាល់ ។

ង- បង្ហាញថាតើ លោកអ្នកគឺជា ឬធ្លាប់ជាភាគទុនិកសំខាន់មួយរូប ក្នុងអំឡុងពេល ១០ ឆ្នាំចុងក្រោយ (មានភាគហ៊ុននិងសិទ្ធិបោះឆ្នោត ចាប់ពីដប់(១០)ភាគរយ ឡើងទៅ) នៃក្រុមហ៊ុនមួយ ឬច្រើន និងចំនួនភាគហ៊ុន ដែលលោកអ្នកបានកាន់កាប់ ។

ច- បង្ហាញពីទំនាក់ទំនងរវាងក្រុមហ៊ុនដែលលោកអ្នកធ្លាប់ទទួលខុសត្រូវឬធ្លាប់មានភាគហ៊ុន និង អ្នកដាក់ ពាក្យសុំអាជ្ញាប័ណ្ណ ។

ឆ- បង្ហាញថាតើលោកអ្នកធ្លាប់ពាក់ព័ន្ធនឹងបណ្តឹងតវ៉ាផ្នែករដ្ឋបាល វិជ្ជាជីវៈ តុលាការ ដែលនាំអោយជាប់ទោសទណ្ឌផ្សេងៗ ទាំងនៅក្នុងប្រទេសកម្ពុជា និងនៅបរទេសដោយសូមបង្ហាញរាល់ពត៌មានលំអិតដែលពាក់ព័ន្ធ ។

ជ- បង្ហាញថា តើលោកអ្នកមានទំនាក់ទំនងល្អជាមួយម្ចាស់កម្ចី ស្ថាប័នតុលាការ ស្ថាប័នក្រៅប្រព័ន្ធតុលាការនៅកម្ពុជានិងនៅបរទេស ដើម្បីសំរួលដល់ការដោះស្រាយបំណុលដែលលោកអ្នកមិនអាចគោរពបានតាមការសន្យាពីមុនមក ។ បញ្ជាក់ថាតើលោកអ្នកដឹងអំពីបណ្តឹងណាមួយ ដែលពាក់ព័ន្ធក្រុមហ៊ុនទាំងឡាយ ដែលលោកអ្នកមានភាគហ៊ុនច្រើននៅក្នុងក្រុមហ៊ុនទាំងនោះ ដោយសូមផ្តល់រាល់ពត៌មានលំអិតដែលពាក់ព័ន្ធ ។

ឈ- បង្ហាញថាតើ លោកអ្នកធ្លាប់បានទទួលការពិន័យ ឬបណ្តេញចេញដោយនិយោជកឬទេ ហើយបើសិនជាមាន សូមផ្តល់រាល់ពត៌មានលំអិត ។

ញ- បង្ហាញថា តើលោកអ្នកមានភាគហ៊ុននៅក្នុងក្រុមហ៊ុន ដែលកំពុងដាក់ពាក្យសុំអាជ្ញាប័ណ្ណ ឬមានបំណងដោយផ្ទាល់ ឬតាមរយៈអន្តរការី ដើម្បីទិញយកភាគហ៊ុនពីក្រុមហ៊ុនដែលកំពុងស្នើសុំអាជ្ញា-ប័ណ្ណ ឬទេ ។

ដ- សូមផ្តល់រាល់ពត៌មានបន្ថែមជូនទៅនិយ័តករធានារ៉ាប់រងទាក់ទងនឹងសមត្ថភាព និងការកាន់តំណែងគ្រប់គ្រង នៅក្នុងក្រុមហ៊ុនដែលកំពុងសុំអាជ្ញាប័ណ្ណ ។

ជំពូក ៣ : ការអនុញ្ញាត និង សោហ៊ុយពាក់ព័ន្ធ

ប្រការ ៧ : ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការសម្រេចចិត្តក្នុងរយៈពេល ៤៥ ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានពាក្យសុំអាជ្ញាប័ណ្ណ រួមទាំងរាល់ឯកសារពាក់ព័ន្ធ ។ ក្នុងករណីចាំបាច់ការអនុញ្ញាតដោយភ្ជាប់នូវលក្ខខណ្ឌពិសេសណាមួយ នឹងត្រូវផ្តល់ជូនដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយបញ្ជាក់នូវកាលកំណត់អំពីការបំពេញលក្ខខណ្ឌនេះ។ ក្នុងករណីដែលលក្ខខណ្ឌមិនត្រូវបំពេញតាមកាលកំណត់ទេនោះ ហើយដោយពុំមានការពន្យាការអនុញ្ញាត ដោយភ្ជាប់លក្ខខណ្ឌនឹងត្រូវអស់សុពលភាពដោយឯកឯង ហើយពុំមានការចេញអាជ្ញាប័ណ្ណដូចនេះទៀតទេ។

ប្រការ ៨ : អាជ្ញាប័ណ្ណមានសុពលភាពសម្រាប់រយៈពេលបី (៣)ឆ្នាំ គិតចាប់ពីថ្ងៃចេញអាជ្ញាប័ណ្ណ។ អាជ្ញាប័ណ្ណនេះអាចស្នើសុំបន្តបានសម្រាប់រយៈពេលបី(៣)ឆ្នាំម្តង ល្គឹកណាតែក្រុមហ៊ុនបានអនុវត្តត្រឹមត្រូវតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។ សោហ៊ុយអាជ្ញាប័ណ្ណមានចំនួនហាសិបលាន (៥០) រៀល ។

ប្រការ ៩ : គ្រប់ក្រុមហ៊ុនធានារ៉ាប់រងត្រូវធ្វើការទូទាត់ជាកាតព្វកិច្ចទៅរាជរដ្ឋាភិបាល តាមការកំណត់ដូចខាងក្រោម :

ក) ក្រុមហ៊ុនធានារ៉ាប់រង ត្រូវបង់ពន្ធទៅរតនាគារជាតិ ដូចមានចែងនៅក្នុងច្បាប់ស្តីពីសារពើពន្ធនៃព្រះរាជាណាចក្រកម្ពុជា ។

ខ) ក្រុមហ៊ុនធានារ៉ាប់រងត្រូវបង់ ០,៥ភាគរយ នៃបុព្វលាភដុល ទៅនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ដើម្បីទូទាត់លើចំណាយក្នុងការផ្សព្វផ្សាយសម្រាប់អភិវឌ្ឍវិស័យធានារ៉ាប់រងនៅកម្ពុជា ។

ជំពូក ៤ : ការពន្យារ និងការដកហូតអាជ្ញាប័ណ្ណ

ប្រការ ១០ : រដ្ឋមន្ត្រី អាចដកហូតអាជ្ញាប័ណ្ណពីក្រុមហ៊ុនធានារ៉ាប់រងតាមសំណើរបស់នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ប្រសិនបើ :

ក) ក្រុមហ៊ុនដែលទទួលអាជ្ញាប័ណ្ណឱ្យធ្វើអាជីវកម្ម បានបញ្ឈប់ការលក់បណ្ណសន្យាធានារ៉ាប់រងថ្មីដូចបានកំណត់ឡើងក្នុងអាជ្ញាប័ណ្ណ ។

ខ) ក្រុមហ៊ុនដែលកំពុងធ្វើអាជីវកម្ម ធ្វើឱ្យខូចខាតដល់ផលប្រយោជន៍របស់អតិថិជន ។

គ) ក្រុមហ៊ុនបាន និងកំពុងប្រព្រឹត្តល្មើសទៅនឹងបទប្បញ្ញត្តិទាំងឡាយនៃច្បាប់ស្តីពីការធានារ៉ាប់រង និង បទប្បញ្ញត្តិដទៃទៀត ។

ឃ) ក្រុមហ៊ុនធានារ៉ាប់រង ឬនាយក ឬបុគ្គលិកទទួលខុសត្រូវគ្រប់គ្រង បានផ្តល់ព័ត៌មានមិនពិតមិនជាក់លាក់ ឬបានបិទបាំង ឬមិនបង្ហាញការពិតនៅក្នុងពាក្យស្នើសុំអាជ្ញាប័ណ្ណ ដែលមានចែងនៅក្នុងប្រកាសនេះ ។

ង) ក្រុមហ៊ុនធានារ៉ាប់រង ឬនាយក ឬបុគ្គលិកទទួលខុសត្រូវគ្រប់គ្រង ត្រូវបានផ្តន្ទាទោសពីការប្រព្រឹត្តល្មើសទៅនឹងច្បាប់ធានារ៉ាប់រង ឬបទប្បញ្ញត្តិផ្សេងទៀត ឬការប្រព្រឹត្តល្មើសដែលទាក់ទងនឹងការក្លែងបន្លំ ឬការមិនស្មោះត្រង់ដូចមានចែងនៅក្នុងច្បាប់ និងបទបញ្ញត្តិជាធរមានផ្សេងៗ ។

ច) ក្រុមហ៊ុនធានារ៉ាប់រង មិនមានលទ្ធភាពបំពេញកាតព្វកិច្ចហិរញ្ញវត្ថុ ឬកាតព្វកិច្ចផ្សេងទៀត ។

ឆ) ក្រុមហ៊ុនធានារ៉ាប់រង បាននិងកំពុងសម្រុះសម្រួលដោះស្រាយជាមួយម្ចាស់បំណុល ឬបានឈានចូលដល់ដំណាក់កាលដែលត្រូវជម្រះបញ្ជី ឬត្រូវបានរំលាយតាមរបៀបផ្សេងទៀត ។

ជ) ក្រុមហ៊ុនធានារ៉ាប់រង ដែលស្ថិតក្នុងករណីមានសាលក្រមរបស់តុលាការតែងតាំងឱ្យមានអ្នកមកទទួល ឬគ្រប់គ្រងទ្រព្យសម្បត្តិរបស់ក្រុមហ៊ុននោះ ។

ឈ) កម្មសិទ្ធិលើទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ត្រូវបានប្រគល់ទៅឱ្យម្ចាស់បំណុល ឬអ្នកតំណាងរបស់ម្ចាស់បំណុល ទៅតាមបន្ទុកដែលមានលើទ្រព្យសម្បត្តិនោះ ។

ញ) ក្រុមហ៊ុន មិនបានធ្វើការធានារ៉ាប់រងបន្តឱ្យបានសមស្របទៅនឹងអាជីវកម្មរបស់ខ្លួន ។

ដ) ផលប្រយោជន៍របស់អ្នកប្រើប្រាស់តម្រូវអោយមានការដកហូតអាជ្ញាបណ្ណនេះ ។

ប្រការ ១១

ក) ក្នុងករណីដែលអាជ្ញាប័ណ្ណនឹងត្រូវដកហូត សេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរមួយដែលបញ្ជាក់អំពីមូលហេតុនៃការដកហូត នឹងត្រូវផ្ញើជូនទៅក្រុមហ៊ុនធានារ៉ាប់រងនោះ ។

ខ) ក្រុមហ៊ុន ត្រូវបានផ្តល់ឱកាសអោយឆ្លើយតបជាលាយលក្ខណ៍អក្សរ ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងរយៈពេលដប់បួន(១៤)ថ្ងៃ គិតចាប់ពីថ្ងៃចេញសេចក្តីជូនដំណឹង ។

គ) ក្នុងករណីដែលនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ មិនបានទទួលការឆ្លើយតបជាលាយលក្ខណ៍អក្សរ នៅក្នុងអំឡុងពេលដែលបានកំណត់នៅក្នុងចំណុច (ខ) រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងដកហូតអាជ្ញាប័ណ្ណតាមការជូនដំណឹងជាលាយលក្ខណ៍អក្សរ ។

ឃ) ក្នុងករណីដែលបានទទួលការឆ្លើយតបជាលាយលក្ខណ៍អក្សរ បន្ទាប់ពីមានការពិចារណាលើការឆ្លើយតបនេះ ក្រសួងនឹងជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការសម្រេចចិត្ត ។

ង) ក្នុងករណីដែលក្រសួងសម្រេចថា មិនដកហូតអាជ្ញាប័ណ្ណទេនោះ ការដាក់លក្ខខណ្ឌទៅលើការបន្តអនុវត្តអាជ្ញាប័ណ្ណនឹងធ្វើឡើងតាមរយៈសេចក្តីជូនដំណឹង ។

ប្រការ ១២ : ក្រុមហ៊ុនដែលមិនពេញចិត្តចំពោះការដកហូតអាជ្ញាប័ណ្ណ អាចប្តឹងតវ៉ាចំពោះសេចក្តីសម្រេចនោះទៅតុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេលដប់បួន(១៤)ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានសេចក្តីសម្រេចនេះ ។

ប្រការ ១៣ : រដ្ឋមន្ត្រី និងមន្ត្រីនៃនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ឬបុគ្គលផ្សេងទៀតដែលបំពេញការងារតាមការណែនាំរបស់រដ្ឋមន្ត្រី ឬនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នឹងមិនអាចត្រូវប្តឹងចំពោះការបំពេញ

មុខងារ និងភារៈកិច្ចរបស់ខ្លួន ដែលមានចែងនៅក្នុងប្រការ ១០ នៃប្រកាសនេះ ប្រសិនបើការបំពេញការងារនោះ ត្រូវបានធ្វើឡើងសុចរិតភាព ។

ជំពូក ៥ : បទប្បញ្ញត្តិផ្សេងទៀត

ប្រការ ១៤ : កាលណាមានការទិញយកភាគហ៊ុននៅក្នុងក្រុមហ៊ុនធានារ៉ាប់រង ដែលធ្វើឱ្យភាគទុនិកកើនចាប់ពីដប់(១០) ភាគរយនៃភាគហ៊ុនរបស់ក្រុមហ៊ុនឡើងទៅ ភាគទុនិកនោះត្រូវផ្ញើជីវប្រវត្តិសង្ខេប និងភ្ជាប់មកជាមួយនូវកម្រងសំណួរ មកនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រួមទាំងប្រភពនៃដើមទុន ដែលប្រើសម្រាប់ទិញភាគហ៊ុននោះ។ ភាគហ៊ុនដែលបានទិញដោយមិនមានការឯកភាពជាមុននឹងមិនផ្តល់នូវសិទ្ធិអំណាច ឬការទទួលស្គាល់នោះទេ ដរាបណាមិនទាន់បានទទួលការឯកភាព ។

ប្រការ ១៥ : ក្នុងករណីមានការតែងតាំងអគ្គនាយកថ្មី ឬមានការផ្លាស់ប្តូរបុគ្គលទាំងឡាយណា (មានបញ្ជាក់នៅក្នុងប្រការ ៤) ដែលទទួលខុសត្រូវគ្រប់គ្រងក្រុមហ៊ុនប្រកបដោយប្រសិទ្ធភាព បុគ្គលដែលត្រូវតាំងថ្មីទាំងនោះត្រូវផ្ញើជីវប្រវត្តិសង្ខេប ដោយភ្ជាប់មកជាមួយនូវកម្រងសំណួរ ដែលបានចែងនៅក្នុងប្រការ ៦ មកនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើកលែងតែ ក្នុងករណីដែលមានការតែងតាំង ឬការជំនួសជាបន្ទាន់ ក្រុមហ៊ុនត្រូវផ្តល់ឯកសារទាំងនោះ អោយបានមួយ(១)ខែមុនពេលដែលបុគ្គលនោះចូលកាន់តំណែង ។

ប្រការ ១៦ : ប្រសិនបើ នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ រកឃើញថាបុគ្គលទាំងឡាយណា ដែលកំពុងបម្រើការងារជាអគ្គនាយក ឬបុគ្គលដែលទទួលខុសត្រូវគ្រប់គ្រងក្រុមហ៊ុនឱ្យមានប្រសិទ្ធភាព មិនមានសមត្ថភាព ឬមិនមានលក្ខណៈសម្បត្តិ គ្រប់គ្រាន់ក្នុងការកាន់តំណែងនោះទេ នាយកដ្ឋានអាចបញ្ជាឱ្យដកបុគ្គលនោះពីតំណែង ក្នុងរយៈពេលមួយដែលកំណត់នៅក្នុងលិខិតដោយឡែកមួយ ។ ក្នុងករណីដែលក្រុមហ៊ុនជឿជាក់ថាការបញ្ជាឱ្យដកតំណែងនោះ មានមូលដ្ឋានលើព័ត៌មានមិនពិត ឬជាការភាន់ច្រឡំ អាចប្តឹងជំទាស់នឹងលិខិតបញ្ជានេះ នៅរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងរយៈពេល ដប់ (១០)ថ្ងៃ គិតចាប់ពីថ្ងៃទទួលលិខិតបញ្ជានោះ។ ប្រសិនបើ រដ្ឋមន្ត្រីឯកភាពជាមួយនឹងការចេញលិខិតបញ្ជានោះ ក្នុងរយៈពេលដប់(១០)ថ្ងៃ គិតចាប់ពីថ្ងៃប្តឹងជំទាស់ លិខិតបញ្ជានោះនឹងត្រូវចូលជាធរមាន។

ប្រការ ១៧ : ក្រុមហ៊ុន ត្រូវជូនដំណឹងនូវរាល់ការផ្លាស់ប្តូរផ្សេងទៀតនៃស្ថានភាពគតិយុត្តិ និងហិរញ្ញវត្ថុ ទៅនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីសុំការអនុម័ត ។ ឯកសារស្នើសុំត្រូវភ្ជាប់មកជាមួយនូវការពិពណ៌នាអំពីមូលហេតុនៃការផ្លាស់ប្តូរប្រតិបត្តិការ ដោយរួមមានព័ត៌មានដូចតទៅ :

ក) ការពង្រីក ឬការកែប្រែសកម្មភាព : ត្រូវផ្តល់ព័ត៌មានដែលមានចែងនៅក្នុងវាក្យខណ្ឌទី ១១ នៃ

ប្រការ ៤ នៃប្រកាសនេះ ។

ខ) ការបន្ថយដើមទុនៈ ការពិពណ៌នាពីលក្ខខណ្ឌដូចជា លក្ខខណ្ឌគតិយុត្តិ និងគណនេយ្យ ហើយ និងការបង្ហាញតួលេខថ្មីនៃមូលនិធិផ្ទាល់ ព្រមទាំងផលប៉ះពាល់ដល់ប្រតិបត្តិការអាជីវកម្ម នាពេលអនាគត និងអនុបាតប្រុងប្រយ័ត្ន ។

គ) ការផ្លាស់ប្តូរទម្រង់គតិយុត្តិ ៖ សេចក្តីព្រាងវិសោធនកម្មនៃលក្ខន្តិកៈក្រុមហ៊ុន និង ពត៌មានដែល ពាក់ព័ន្ធនឹងគណៈគ្រប់គ្រង។

ឃ) ការផ្លាស់ប្តូរប្រភេទអាជីវកម្ម ៖ សេចក្តីព្រាងវិសោធនកម្មនៃលក្ខន្តិកៈក្រុមហ៊ុន

ក្រុមហ៊ុនត្រូវរាយការណ៍នូវរាល់ការផ្លាស់ប្តូរទាំងអស់នេះ ដល់នាយកដ្ឋានឧស្សាហកម្ម និង ហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ យ៉ាងហោចណាស់ពីរ(២)ខែ មុនពេលដែលការ ផ្លាស់ប្តូរកើតឡើង បើពុំនោះទេ សម្រាប់រយៈពេលជូនដំណឹងខ្លីជាងនេះ ត្រូវមានការឯកភាពពី នាយកដ្ឋាន ឧស្សាហកម្មហិរញ្ញវត្ថុ ។

ប្រការ ១៨ ៖ ក្រុមហ៊ុនធានារ៉ាប់រង ដែលទទួលបានអាជ្ញាប័ណ្ណ អាចបើកសាខាការិយាល័យក្នុងស្រុកនៅក្នុង ព្រះរាជាណាចក្រកម្ពុជា ដោយគ្រាន់តែមានការឯកភាពជាមុនពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប៉ុណ្ណោះ ។

ប្រការ ១៩ ៖ បុគ្គលណាដែលប្រព្រឹត្តផ្ទុយនឹងបទប្បញ្ញត្តិនៃប្រកាសនេះ នឹងត្រូវទទួលការផាកពិន័យជាប្រាក់ ចំនួន ១០លានរៀល បង់ចូលរតនាគារជាតិ ។

ប្រការ ២០ ៖ ប្រកាសលេខ ៨៦៤ សហវ ចុះថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ២០០១ ត្រូវទុកជានិរាករណ៍ ។ បទប្បញ្ញត្តិ ដទៃទៀតណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ដែរ ។

ប្រការ ២១ ៖ ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០០៧

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

ចម្លងជូន ៖

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១៧០ សហវ.ប.ក

ប្រកាសអន្តរក្រសួង
ស្ដីពី
ការកំណត់ និង កែសម្រួលប្រាក់ឧបត្ថម្ភគោលនយោបាយប្រចាំខែ ជូនកូនរបស់គ្រួសារជនពលី និង មរណៈ

- ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០២/១២៤, ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤, ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និង ប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១, ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក, ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៥ ស្ដីពីការរៀបចំ និង ប្រព្រឹត្តទៅរបស់ក្រសួង សង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨, ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការ បង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក, ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្ដីពីការរៀបចំ និង ប្រព្រឹត្តទៅរបស់ក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក, ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៤ ស្ដីពីការបំពេញបន្ថែម និង កែសម្រួលនាយកដ្ឋាន មួយចំនួននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៨ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០០៧ របស់រាជរដ្ឋាភិបាលកម្ពុជា ស្ដីពីរបបឧបត្ថម្ភ ចំពោះយោធិនពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និង ពិការ
- បានឃើញសេចក្ដីសម្រេច ២០ សសរ, ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ១៩៩១ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្ដីពីរបបគោលនយោបាយ ចំពោះជនពលី ពិការ និង លិខិតលេខ ៥១៥ សជណ អវ.ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៩១ របស់រដ្ឋមន្ត្រីទទួលបន្ទុកខុទ្ទកាល័យ ក្រុមប្រឹក្សារដ្ឋមន្ត្រី
- យោងមតិណែនាំដ៏ខ្ពង់ខ្ពស់របស់សម្ដេចនាយករដ្ឋមន្ត្រី ក្នុងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីនៅថ្ងៃទី ១៩ ខែ មករា ឆ្នាំ២០០៧
- យោងចំណារដ៏ខ្ពង់ខ្ពស់របស់សម្ដេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៧ លើលិខិតលេខ ២៩៩ សហវ.ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០០៧ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ស ម្រេ ច

ប្រការ ១ ៖ ត្រូវបានតំឡើងប្រាក់ឧបត្ថម្ភគោលនយោបាយប្រចាំខែ ជូនកូនគ្រួសារជនពលី និង មរណៈរបស់អតីតយោធិន នៃកងយោធពលខេមរភូមិន្ទ និង កងកម្លាំងនគរបាលជាតិ ពី ៤.០០០ រៀល (បួនពាន់រៀល) ទៅ ៨.០០០ រៀល (ប្រាំបីពាន់រៀល) សំរាប់កូនម្នាក់ ។

ប្រការ ២ ៖ បទប្បញ្ញត្តិណា ដែលផ្ទុយនឹងខ្លឹមសារនៃប្រការ ១ ខាងលើ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៣ ៖ ប្រកាសអន្តរក្រសួងនេះ មានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៧ នេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែ មីនា ឆ្នាំ ២០០៧

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

រដ្ឋមន្ត្រី
ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា

ចម្លងជូន

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់សាលាខេត្ត ក្រុង ដើម្បីអនុវត្ត
- ឯកសារ និង កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការ និង សាសនា

លេខ ៤១ ក.ធ.ស/ប្រក

រាជធានីភ្នំពេញ,ថ្ងៃទី១៦ ខែ មីនា ឆ្នាំ ២០០៧

លិខិតចូល
ថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៧

ប្រកាស

ស្តីពីការបង្កើតសាលាពុទ្ធិកអនុវិទ្យាល័យកៀនស្វាយ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/ ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ នស / ៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ នឹងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ-បក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ នឹងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និងសាសនា
- យោងតាមចំណារបញ្ជូនលេខ ០១៣ ធ.ក.ខ ចុះថ្ងៃទី០៥ ខែកុម្ភៈឆ្នាំ២០០៧ របស់មន្ទីរធម្មការ និង សាសនាខេត្តកណ្តាល
- យោងតាមចំណារបញ្ជូនលេខ ១១១ ស.ណ ចុះថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ ២០០៧ របស់អភិបាលខេត្តកណ្តាល
- យោងតាមការចាំបាច់របស់អធិការដ្ឋានពុទ្ធិកសិក្សា ដើម្បីអភិវឌ្ឍន៍ពុទ្ធិកសិក្សា ។

សំរេច

ប្រការ ១ : ត្រូវបានបង្កើតសាលា **ពុទ្ធិកអនុវិទ្យាល័យកៀនស្វាយ** ដែលមានទីតាំងនៅក្នុង វត្តមុនីសាគរ ឃុំក្បាលកោះ ស្រុកកៀនស្វាយ ខេត្តកណ្តាល ។

ប្រការ ២ : សាលាពុទ្ធិកអនុវិទ្យាល័យ **កៀនស្វាយ** ជាគ្រឹះស្ថានពុទ្ធិកសិក្សា ស្ថិតនៅក្រោមការដឹកនាំរបស់មន្ទីរ ធម្មការ និង សាសនា ខេត្តកណ្តាល និងការណែនាំមុខជំនាញបច្ចេកទេស របស់អគ្គាធិការដ្ឋាន ពុទ្ធិកសិក្សាជាតិ នៃក្រសួងធម្មការ និង សាសនា ។

ប្រការ ៣ : សាលាពុទ្ធិកអនុវិទ្យាល័យនេះ ត្រូវអនុវត្តដំណើរការសិក្សា ពីឆ្នាំសិក្សា ២០០៧-២០០៨ តទៅ ។

ប្រការ ៤ : រាល់សេចក្តីប្រកាសទាំងឡាយណាដែលផ្ទុយពីសេចក្តីប្រកាសខាងលើនេះ ទុកជានិរាករណ៍ ។

ប្រការ ៥ : អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ការិយាល័យបុគ្គលិកមន្ទីរធម្មការ និងសាសនាខេត្តកណ្តាល មានភារកិច្ចរៀងៗខ្លួនអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

ឃុន_ហ៊ាង

ចម្លងជូន :

- សម្តេចព្រះអគ្គមហាសង្ឃរាជ
- សម្តេចគណៈព្រះសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងអប់រំយុវជន និងកីឡា
- ព្រះមេគណរាជធានីភ្នំពេញ

" ដើម្បីថ្វាយ-ប្រគេន-ជូនជ្រាបជាពតិមាន "

- ដូចប្រការ២ " ដើម្បីអនុវត្ត "
- រាជកិច្ចកិច្ច " ដើម្បីចុះផ្សាយ "
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការ និង សាសនា

លេខ ...៤២...... ក.ធ.ស ប្រក

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែ មករា ឆ្នាំ ២០០៧

លិខិតចូល
ថ្ងៃទី ២១ ខែ ០១ ឆ្នាំ 2007

ប្រកាស

ស្តីពីការបង្កើតសាលាពុទ្ធិកអនុវិទ្យាល័យសម្តេច ជា ស៊ីម វត្តត្រពាំងឈូក

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/ ០៧០៤ / ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ-បក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និងសាសនា
- យោងតាមចំណារបញ្ជូនលេខ ៣៩៦ ប.ជ ចុះថ្ងៃទី១៦ ខែ តុលា ឆ្នាំ ២០០៦ របស់មន្ទីរធម្មការ និង សាសនារាជធានីភ្នំពេញ
- យោងតាមការចាំបាច់របស់អធិការដ្ឋានពុទ្ធិកសិក្សា ដើម្បីអភិវឌ្ឍន៍ពុទ្ធិកសិក្សា ។

សំរេច

ប្រការ ១ : ត្រូវបានបង្កើតសាលា **ពុទ្ធិកអនុវិទ្យាល័យសម្តេច ជា ស៊ីម វត្តត្រពាំងឈូក** ដែលមានទីតាំងនៅក្នុងវត្តត្រពាំងឈូក សង្កាត់ សំរោងក្រោម ខ័ណ្ឌ ដង្កោ រាជធានីភ្នំពេញ ។

ប្រការ ២ : សាលាពុទ្ធិកអនុវិទ្យាល័យសម្តេច **ជា ស៊ីម វត្តត្រពាំងឈូក** ជាគ្រឹះស្ថានពុទ្ធិកសិក្សា ស្ថិតនៅក្រោមការដឹកនាំរបស់មន្ទីរធម្មការ និង សាសនា រាជធានីភ្នំពេញ និង ការណែនាំមុខជំនាញបច្ចេកទេសរបស់អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ នៃក្រសួងធម្មការ និង សាសនា ។

ប្រការ ៣ : សាលាពុទ្ធិកអនុវិទ្យាល័យនេះ ត្រូវអនុវត្តដំណើរការសិក្សា ពីឆ្នាំសិក្សា ២០០៧-២០០៨ តទៅ ។

ប្រការ ៤ : រាល់សេចក្តីប្រកាសទាំងឡាយណាដែលផ្ទុយពីសេចក្តីប្រកាសខាងលើនេះ ទុកជានិរាករណ៍ ។

ប្រការ ៥ : អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ នាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ ការិយាល័យបុគ្គលិកមន្ទីរ-ធម្មការ និង សាសនា រាជធានីភ្នំពេញ មានភារកិច្ចរៀងៗខ្លួនអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

ឃុន ហ៊ាង

ចម្លងជូន :

- សម្តេចព្រះអគ្គមហាសង្ឃរាជ
- សម្តេចគណៈព្រះសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងអប់រំយុវជន និងកីឡា
- ព្រះមេគណរាជធានីភ្នំពេញ

" ដើម្បីថ្វាយ-ប្រគេន-ជូនជ្រាបជាពតិមាន "

- ដូចប្រការ២ " ដើម្បីអនុវត្ត "
- រាជកិច្ចកិច្ច " ដើម្បីចុះផ្សាយ "
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការ និង សាសនា

លេខ ៤៣ ក.ធ.ស

រាជធានីភ្នំពេញ,ថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០០៧

លិខិតចូល
ថ្ងៃទី ២០ ខែ មីនា ឆ្នាំ 20០៧

ប្រកាស

ស្តីពីការបង្កើតសាលាពុទ្ធិកអនុវិទ្យាល័យ វត្តសិត្បូ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/ ០៧០៤ / ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ-បក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និងសាសនា
- យោងតាមចំណារបញ្ជូនលេខ ០១៦ ធ.ក.ខ ចុះថ្ងៃទី១២ ខែកុម្ភៈឆ្នាំ២០០៧ របស់មន្ទីរធម្មការ និង សាសនា ខេត្តកណ្តាល
- យោងតាមការចាំបាច់របស់អធិការដ្ឋានពុទ្ធិកសិក្សា ដើម្បីអភិវឌ្ឍន៍ពុទ្ធិកសិក្សា ។

សំ រេ ច

ប្រការ ១ : ត្រូវបានបង្កើតសាលា **ពុទ្ធិកអនុវិទ្យាល័យ ទត្តសិត្ស** ដែលមានទីតាំងនៅក្នុង វត្តសិត្ស ឃុំ សិត្ស ស្រុក ស្អាង ខេត្ត កណ្តាល ។

ប្រការ ២ : សាលាពុទ្ធិកអនុវិទ្យាល័យ **ទត្តសិត្ស** ជាគ្រឹះស្ថានពុទ្ធិកសិក្សា ស្ថិតនៅក្រោមការដឹកនាំរបស់ មន្ទីរធម្មការ និងសាសនា ខេត្តកណ្តាល និងការ... មុខជំនាញបច្ចេកទេស របស់អគ្គាធិការដ្ឋាន ពុទ្ធិកសិក្សាជាតិ នៃក្រសួងធម្មការ និង សាសនា ។

ប្រការ ៣ : សាលាពុទ្ធិកអនុវិទ្យាល័យនេះ ត្រូវអនុវត្តដំណើរការសិក្សា...ឆ្នាំសិក្សា ២០០៧-២០០៨ តទៅ ។

ប្រការ ៤ : រាល់សេចក្តីប្រកាសទាំងឡាយណាដែលផ្ទុយពីសេចក្តីប្រកាសខាងលើនេះ ទុកជានិរាករណ៍ ។

ប្រការ ៥ : អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ការិយាល័យបុគ្គលិក មន្ទីរ ធម្មការ និងសាសនាខេត្តកណ្តាល មានភារកិច្ចរៀងៗខ្លួនអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

ឃឹុន - ហ៊ាង

ចម្លងជូន :

- សម្តេចព្រះអគ្គមហាសង្ឃរាជ
- សម្តេចគណៈព្រះសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងអប់រំយុវជន និងកីឡា
- ព្រះមេគណរាជធានីភ្នំពេញ

" ដើម្បីថ្វាយ-ប្រគេន-ជូនជ្រាបជាពត៌មាន "

- ដូចប្រការ២ " ដើម្បីអនុវត្ត "
- រាជកិច្ចកិច្ច " ដើម្បីចុះផ្សាយ "
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការ និង សាសនា

លេខ ៦៤ ធ.ធ.សហ

រាជធានីភ្នំពេញ,ថ្ងៃទី ១២ ខែ មិនា ឆ្នាំ ២០០៧

លិខិតចូល
ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៧

ប្រកាស
ស្តីពីការបង្កើតសាលាពុទ្ធិកវិទ្យាល័យ ក្រពើហា

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/ ០៧០៤ / ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល ណៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ នឹងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ-បក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ នឹងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និងសាសនា
- យោងតាមចំណារបញ្ជូនលេខ ០២៣ ធ.ក.ខ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០៧ របស់មន្ទីរធម្មការ និងសាសនា ខេត្តកណ្តាល
- យោងតាមការចាំបាច់របស់អធិការដ្ឋានពុទ្ធិកសិក្សា ដើម្បីអភិវឌ្ឍន៍ពុទ្ធិកសិក្សា ។

ស ំ រេ ច

ប្រការ ១ : ត្រូវបានបង្កើតសាលា **ពុទ្ធិកវិទ្យាល័យ ត្រពាំងរុស្ស៊ី** ដែលមានទីតាំងនៅក្នុងវត្ត ប្រជុំនទី " **ត្រពាំងរុស្ស៊ី** " ឃុំ ព្រែកឫស្សី ស្រុក តាខ្មៅ ខេត្ត កណ្តាល ។

ប្រការ ២ : សាលាពុទ្ធិកវិទ្យាល័យ **ត្រពាំងរុស្ស៊ី** ជាគ្រឹះស្ថានពុទ្ធិកសិក្សា ស្ថិតនៅក្រោមការដឹកនាំរបស់មន្ទីរធម្មការ និង សាសនា ខេត្តកណ្តាល និង ការណែនាំមុខជំនាញបច្ចេកទេស របស់អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ នៃក្រសួងធម្មការ និង សាសនា ។

ប្រការ ៣ : សាលាពុទ្ធិកវិទ្យាល័យនេះ ត្រូវអនុវត្តដំណើរការសិក្សា ពីឆ្នាំសិក្សា ២០០៧-២០០៨ តទៅ ។

ប្រការ ៤ : រាល់សេចក្តីប្រកាសទាំងឡាយណាដែលផ្ទុយពីសេចក្តីប្រកាសខាងលើនេះ ទុកជានិរាករណ៍ ។

ប្រការ ៥ : អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ នាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ ការិយាល័យបុគ្គលិក មន្ទីរធម្មការ និង សាសនា ខេត្តកណ្តាល មានភារកិច្ចរៀងៗខ្លួនអនុវត្តតាមប្រកាសនេះ ឱ្យមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ចម្លងជូន :

- សម្តេចព្រះអគ្គមហាសង្ឃរាជ
- សម្តេចគណៈព្រះសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងអប់រំយុវជន និងកីឡា
- ព្រះមេគណ

" ដើម្បីថ្វាយ-ប្រគេន-ជូនជ្រាបជាពតិមាន "

- ដូចប្រការ២ " ដើម្បីអនុវត្ត "
- រាជកិច្ចកិច្ច " ដើម្បីចុះផ្សាយ "
- ឯកសារ កាលប្បវត្តិ

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

ឃុន ហ៊ាង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ០០០៤ ពណ.ចតក

ភ្នំពេញថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០០៧

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន	:	**ស៊ឹម ហ្គោល អ៊ិនធើណេសិនណល ខូ អិលធីឌី** **SAEM GOL INTERNATIONAL Co., Ltd.**
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម	:	Co. 9344/06P ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៦
មានទ្រង់ទ្រាយជា	:	ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត
២- អភិបាលក្រុមហ៊ុន	:	លោកស្រី **នាង សុគុនគេត** ប្រធានក្រុមប្រឹក្សាភិបាល លោក KIM CHUNG IN អភិបាល
៣- ដើមទុនក្រុមហ៊ុន	:	ចំនួន ២០.០០០.០០០ រៀល
៤- ទីស្នាក់ការក្រុមហ៊ុន	:	ផ្ទះលេខ ១៨៥ ផ្លូវលេខ ២៧១ សង្កាត់ទឹកថ្លា ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។
៥- កម្មវត្ថុអាជីវកម្ម	:	-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ ទីហ៊ីរណ៍ អាហ៊ីរណ៍ទំនិញ នាំចូលឱសថ និងសំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ -ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ -ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង -ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ -មន្ទីរពេទ្យពិគ្រោះនិងព្យាបាលជំងឺ -បើកសាលារៀន -សេវាយកក័រៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម -សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ និងពាណិជ្ជកម្ម -សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស -សេវាផ្សាយពាណិជ្ជកម្ម -បោះពុម្ពផ្សាយ -ផលិតខ្សែភាពយន្ត និង វីដេអូ CD -ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូនទំនិញនិងចែកចាយទំនិញ -សេវាយកក័រៃជើងសារលើការដឹកជញ្ជូន -សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់ និងស្ពាប្បករ -ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត -វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ. ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

ម_ស៊ីថន

<u>ចំលងជូន</u>

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ០០០៦ ពណ.នគក

ភ្នំពេញថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០០៧

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ខ្មែរ សុភមង្គល គ្រុប**
KHMER SOPHEAKMONGKOL GROUP Co., Ltd.
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 3312/07E ចុះថ្ងៃទី ០២ ខែ មករា ឆ្នាំ ២០០៧
មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **គីម ខេង** ប្រធានក្រុមប្រឹក្សាភិបាល
លោក **JEFFERSON LE** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.000.000 រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ២០ DE₀ ផ្លូវលេខ ២៨៨ ក្រុមទី២៣ សង្កាត់បឹងកេងកងទី២ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ និងសំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកព័ត៌មានដើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូននិងចែកចាយទំនិញ
-សេវាយកព័ត៌មានដើងសារលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ហត្ថលេខានិងត្រា៖ ចាម ប្រសិទ្ធ

ចំលងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ០០០៧ ពណ.ចតក

ភ្នំពេញថ្ងៃទី ០៣ ខែមករា ឆ្នាំ ២០០៧

ឯកសារជូនដំណឹង រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន	: **អិល.វី.ស៊ី. ខនស្ទេន** **L. V. C. CONSTANT Co., Ltd.**
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម	: **Co. 9325/06P** ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០៦
មានទ្រង់ទ្រាយជា	: ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត
២- អភិបាលក្រុមហ៊ុន	: លោក **ខៀវ វិសេស**
៣- ដើមទុនក្រុមហ៊ុន	: ចំនួន ៥០.០០០.០០០ រៀល
៤- ទីស្នាក់ការក្រុមហ៊ុន	: ផ្ទះលេខ ៦០ ផ្លូវលេខ ៤៤០ សង្កាត់ទួលទំពូងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ
៥- កម្មវត្ថុអាជីវកម្ម	: -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរណ៍ អាហរណ៍ទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ -ការជួលដាក់ឃ្លាំងទុកផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ -ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង -ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ -មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ -បើកសាលារៀន -សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម -សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម -សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស -សេវាផ្សាយពាណិជ្ជកម្ម -បោះពុម្ពផ្សាយ -ផលិតខ្សែភាពយន្ត វីដេអូ CD -ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូននិងចែកចាយទំនិញ -សេវាយកកំរៃជើងសារលើការដឹកជញ្ជូន -សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់ -ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត -វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ទេសរដ្ឋមន្ត្រី

[illegible]ពាណិជ្ជកម្ម

[illegible]ការ

គឹម_ស៊ីថន

<u>ចំលងជូន</u>

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ០០៧១ ពណ.ឧតត

ភ្នំពេញថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០០៧

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ស៊ីធីស្តារ អ៊ិនវេសមេន**
CityStar Investment Co., Ltd.
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 3295/06E ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០៦
មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក Jean- Louis CHARON ប្រធានក្រុមប្រឹក្សាភិបាល
លោក BERNARD, RAYMOND, JACQUES BABOT អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ៤.000.000 រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : សណ្ឋាគារ AMANJAYA PANCAM វិថីព្រះស៊ីសុវត្ថិ កែងផ្លូវលេខ ១៥៤ សង្កាត់ផ្សារកណ្តាលទី១ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម :
-ភ្នាក់ងារពាណិជ្ជកម្ម-សេវាយកកំរៃជើងសារ -តំណាងពាណិជ្ជកម្ម
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូល ឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ផលិត ទិញ លក់ គ្រឿងអលង្ការ ប្តូរប្រាក់
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស ... និងចែកចាយទំនិញ
-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន រមណីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ. ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

[illegible]ធិការ

ចាម ប្រសិទ្ធ

ចំលងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ